**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
**នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

# គោលការណ៍ណែនាំ
# ស្តីពី
# ការចូលរួមជាសាធារណៈ
# នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កំណែថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

# មាតិកា


**ជំពូក ១: គោលការណ៍ទូទៅ** ........ 1

**១. សេចក្តីផ្តើម** ........ 1

**២. គោលបំណងនៃការចូលរួមជាសាធារណៈ និងគោលការណ៍ណែនាំនេះ** ........ 2

**៣. គោលការណ៍នៃការចូលរួមជាសាធារណៈ** ........ 2

៣.១. គោលការណ៍ទទួលបានព័ត៌មាន ........ 3

៣.២. គោលការណ៍នៃការចូលរួមជាសាធារណៈ ........ 3

៣.៣. គោលការណ៍នៃការទទួលបាននូវយុត្តិធម៌សង្គម និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ........ 4

៣.៤. គោលការណ៍ សមភាពយេនឌ័រនៅក្នុងការចូលរួមជាសាធារណៈ ........ 4

៣.៥. គោលការណ៍នៃការលើកកម្ពស់ជនជាតិដើមភាគតិចនៅក្នុងការចូលរួមជាសាធារណៈ ........ 4

៣.៦. គោលការណ៍ផ្សេងៗទៀត ........ 5

**៤. និយមន័យ** ........ 6

**៥. ដំណាក់កាលនានានៃការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** ........ 8

**៦. កម្រិតនៃការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** ........ 9

៦.១. ការជូនដំណឹង ........ 10

៦.២. ការពិគ្រោះយោបល់ ........ 11

៦.៣. ការចូលរួមផ្ទាល់ ........ 11

៦.៤. កិច្ចសហការ ........ 12

៦.៥. ការផ្តល់អំណាច ........ 12

**៧. ការទទួលបានព័ត៌មាននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** ........ 13

**ជំពូក ២: និដ្ឋភាពច្បាប់** 14

**១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦** 14

**២. អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩** 15

**៣.ប្រកាសស្តីពីស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩** 16

**៤. សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព និងភារៈកិច្ច ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** 17

**ជំពូក ៣: នីតិវិធីនៃការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** 18

**១. កម្រិត និងទម្រង់នៃការចូលរួមជាសាធារណៈ** 18

១.១. ការកំណត់រកអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត 18

១.២. លទ្ធផលនៃការចូលរួមជាសាធារណៈ 20

១.៣. ការទទួលបានព័ត៌មាន 21

១.៤. ការកំណត់ពេលវេលានៃការចូលរួមជាសាធារណៈ 22

**២. ដំណាក់កាលចំណាត់ថ្នាក់គម្រោង** 23

២.១. វិធីសាស្ត្រ 23

២.២. រយៈពេល 24

២.៣. លទ្ធផល 24

**៣. ដំណាក់កាលកំណត់វិសាលភាពគម្រោង** 25

៣.១. វិធីសាស្ត្រ និងវិសាលភាព 25

៣.២. រយៈពេល 31

៣.៣. លទ្ធផល ........ 31

**៤. ដំណាក់កាលស៊ើបអង្កេតគម្រោង និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន** 33

៤.១. វិធីសាស្ត្រ ........ 33

៤.២. រយៈពេលកំណត់ ........ 38

៤.៣. លទ្ធផល ........ 39

**៥.ដំណាក់កាលពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការធ្វើសេចក្ដីសម្រេច** ........ 42

៥.១. វិធីសាស្ត្រ និងវិសាលភាព ........ 42

៥.២. រយៈពេល ........ 42

៥.៣. លទ្ធផល ........ 43

**៦. ដំណាក់កាលអង្កេតតាមដានបរិស្ថាន** ........ 44

៦.១. វិធីសាស្ត្រ ........ 44

៦.២. ការអង្កេតតាមដាន ........ 45

**៧. ការផ្អាកគម្រោង ការបិទគម្រោង និងដំណាក់កាលក្រោយការបិទគម្រោង** ........ 46

# ជំពូក ១:

# គោលការណ៍ទូទៅ

## ១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស អាស្រ័យរដ្ឋធម្មនុញ្ញ ដោយយកប្រជជនជាធំក្នុងការអភិវឌ្ឍប្រទេសជាតិ ហើយប្រជាជនគ្រប់រូបមានសិទ្ធិសេរីភាពពេញលេញ ក្នុងការបញ្ចេញមតិ និងប្រឡូកក្នុងការងារនយោបាយ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ជាដើម។

ដើម្បីអភិវឌ្ឍន៍គម្រោងណាមួយ រាជរដ្ឋាភិបាលតម្រូវឱ្យមានការសិក្សា និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុនសិន មុនរាជរដ្ឋាភិបាលសម្រេចចិត្តលើគម្រោងអភិវឌ្ឍនោះ។ នៅក្រោមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) និងអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន ត្រូវធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ។ ទន្ទឹមនឹងនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានការចូលរួមជាសាធារណៈ ទើបការវាយតម្លៃមានប្រសិទ្ធិភាព តម្លាភាព និងយុត្តិធម៌សង្គម ហើយរាជរដ្ឋាភិបាលធ្វើការសម្រេចចិត្តលើគម្រោងមានភាពត្រឹមត្រូវ។ ហេតុនេះ ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមានសារៈសំខាន់បំផុតដែលមិនអាចខ្វះបាន មានន័យថា គ្មានការចូលរួមជាសាធារណៈគឺគ្មានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានន័យថា ការពិគ្រោះយោបល់ និងការពាក់ព័ន្ធជាសាធារណៈក្នុងការពិភាក្សា ការផ្លាស់ប្តូរ ការស្តាប់មតិយោបល់ ការទទួលយកព័ត៌មានពីគ្រប់ភាគីដែលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលពីការអភិវឌ្ឍគម្រោង ។ ការចូលរួមជាសាធារណៈរួមបញ្ចូលនូវ ការចូលរួមដោះស្រាយជម្លោះតាំងពីដំណាក់កាលធ្វើផែនការគម្រោង ការសាងសង់គម្រោង ការអនុវត្តគម្រោង និងការចូលរួមចំណែកក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

ការចូលរួមជាសាធារណៈកើតឡើងនៅគ្រប់ដំណាក់កាលទាំងអស់ នៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាប់តាំងពីដំណាក់កាលចាត់ថ្នាក់គម្រោង ដំណាក់កាលកំណត់វិសាលភាពគម្រោង ដំណាក់កាលនៃការរៀបចំ និងការវាយតម្លៃ និងបន្តរហូតដល់ពេលគម្រោងត្រូវបញ្ចប់ ហើយទីតាំងគម្រោងត្រូវបានស្តារឡើងវិញ ។ ដើម្បីមានប្រសិទ្ធភាព ការចូលរួមជាសាធារណៈមិនគួរត្រូវបានកំណត់ឱ្យមានត្រឹម

តែក្រុមតូចនៃអ្នកពាក់ព័ន្ធដែលគាំទ្រនោះទេ។ ការចូលរួមជាសាធារណៈ រួមបញ្ចូលគ្រប់បុគ្គលទាំងអស់ ដែលមានការចាប់អារម្មណ៍ (ផលប្រយោជន៍) នៅក្នុងគម្រោង ហើយដែលអាចទទួលរងការប៉ះពាល់ ដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ។ អ្នកពាក់ព័ន្ធដែលមានកង្វល់ជាមួយនឹងគម្រោងអភិវឌ្ឍន៍ នឹង រួមបញ្ចូលនូវ ក្រសួង/ស្ថាប័ន អាជ្ញាធរមូលដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា អ្នកតំណាងនៃប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធ ទៅនឹងទីតាំងនៃគម្រោង ។[1]

## ២. គោលបំណងនៃការចូលរួមជាសាធារណៈ និងគោលការណ៍ណែនាំនេះ

គោលបំណងនៃការចូលរួមជាសាធារណៈ នៅក្នុងកិច្ចដំណើរការនៃការចូលរួមជាសាធារណៈ គឺ ផ្តល់ជូនប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត នូវឱកាសក្នុងការ ទទួលបានព័ត៌មាន និងការពិគ្រោះយោបល់អំពីគម្រោង ឬសកម្មភាពនានា ដើម្បីសម្តែងមតិយោបល់អំពី គម្រោង ឬសកម្មភាពនានា និងអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងមានអត្ថន័យ នៅ ក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គោលបំណងនៃគោលការណ៍ណែនាំនេះ គឺដើម្បីផ្តល់ជាមគ្គុទេសក៍ អំពីប្រភេទ និងកម្រិតនៃការ ចូលរួមជាសាធារណៈ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលនីមួយៗ នៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន ដើម្បីសម្រេចបាននូវគោលបំណងជាចម្បងនៃការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

## ៣. គោលការណ៍នៃការចូលរួមជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជាមានការប្តេជ្ញាចិត្ត ក្នុងការការពារនូវសិទ្ធិមនុស្ស ជំរុញគុណភាពនៃការ សម្រេចចិត្ត និងការធ្វើឱ្យមានតម្លាភាពនៃការសម្រេចចិត្ត ។ គោលដៅនេះផ្តល់នូវក្របខណ្ឌសម្រាប់បណ្តា គោលការណ៍ខាងក្រោមនេះ សម្រាប់ការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ ដែលជាមូលដ្ឋាន សម្រាប់គាំទ្រដល់គោលការណ៍ណែនាំនេះ ។

---

[1] ចំណុចនេះបានមកពី ឧបសម្ព័ន្ធ ១ នៃប្រកាសស្តីពីគោលការណ៍ណែនាំទូទៅសម្រាប់ការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ លេខ ៣៧៦ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៩ ។

## ៣.១. គោលការណ៍ទទួលបានព័ត៌មាន

សាធារណៈជន ត្រូវមានសិទ្ធិសមរម្យក្នុងការទទួលបានព័ត៌មាន ដែលទាក់ទងនឹងបរិស្ថាន និងការអភិវឌ្ឍន៍ រួមបញ្ចូល ព័ត៌មានស្ដីពីគម្រោង និងសកម្មភាពដែលបានស្នើឡើង និងសម្ភារៈដែលគ្រោះថ្នាក់នៅក្នុងសហគមន៍របស់ពួកគេ ។ ព័ត៌មានស្ដីពីគម្រោង និងសកម្មភាពដែលបានស្នើឡើង រួមបញ្ចូលផែនការគ្រប់គ្រងបរិស្ថានដែលបានស្នើឡើង និងលិខិតឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាន និងទទួលយកបានយ៉ាងទូលំទូលាយ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងនៅក្នុងលក្ខណៈមួយ ដែលបង្កើតឱកាសជាអតិបរមាសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមបញ្ចូលការអង្កេតតាមដាន និងការអនុលោមតាមច្បាប់ នៅក្នុងអំឡុងពេលនៃប្រតិបត្តិការគម្រោង ។

## ៣.២. គោលការណ៍នៃការចូលរួមជាសាធារណៈ

សាធារណៈជនទាំងឡាយណា ដែលអាចទទួលរងនូវការប៉ះពាល់ ដោយសារការសម្រេចចិត្តណាមួយ ត្រូវមានសិទ្ធិផ្ដល់នូវធាតុចូល (ការចូលរួមមតិយោបល់) ដ៏មានអត្ថន័យ ទាន់ពេលវេលា និងប្រកបដោយការយល់ដឹងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការសម្រេចចិត្តអំពីគម្រោង ឬសកម្មភាពនោះ ត្រូវបានធ្វើឡើង ។ សិទ្ធិក្នុងការផ្ដល់ធាតុចូល (មតិយោបល់) ត្រូវទទួលបាននូវការការពារ និងត្រូវរួចផុតពីការបង្ខិតបង្ខំ ឬ ការគម្រាមកំហែង និងការបំភិតបំភ័យ ។ ពួកគេត្រូវមានសិទ្ធិក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងលក្ខណៈប្រកបដោយការចូលរួម តម្លាភាព និងគណនេយ្យភាពផងដែរ ។ ការចូលរួមនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើកកម្ពស់សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះក្ដីបារម្ភ និងតម្រូវការរបស់សាធារណៈជន ដើម្បីពង្រឹងនូវការមូលមតិគ្នា និងធ្វើឱ្យប្រសើរឡើងចំពោះការទទួលយកនូវ និងការគោរពតាម សេចក្ដីសម្រេចផ្នែកបរិស្ថាន ដោយសារប្រជាពលរដ្ឋយល់ថាខ្លួនបានចូលរួមនៅក្នុងកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

## ៣.៣. គោលការណ៍នៃការទទួលបាននូវយុត្តិធម៌សង្គម និងដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព

សាធារណៈជនមានសិទ្ធិទទួលបាននូវយុត្តិធម៌ រួមបញ្ចូល យន្តការបណ្តឹងដើម្បីទទួលបានដំណោះស្រាយ និងនីតិវិធីបណ្តឹងរដ្ឋបាលត្រឹមត្រូវ នៅក្នុងករណីមានការរំលោភបំពាន ឬការប្រព្រឹត្តិល្មើសដោយភាគីណាមួយនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬ ការខកខានមិនបានអនុលោមតាមផែនការគ្រប់គ្រងបរិស្ថាន ឬការប្តេជ្ញាណាមួយដែលធ្វើឡើងដោយម្ចាស់គម្រោង ។ ប្រជាពលរដ្ឋ អង្គការ និងអង្គភាពស្របច្បាប់ ត្រូវមានសិទ្ធិទទួលបាននូវមធ្យោបាយសមរម្យ ទោះបីផ្នែករដ្ឋបាលក្តី ឬផ្នែកតុលាការក្តី និងទទួលបាននូវដំណោះស្រាយដែលសមរម្យ និងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវការដោះស្រាយវិវាទបរិស្ថាន ។ នីតិវិធី និងដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល គួរតែមានអត្ថិភាព ដើម្បីពង្រឹងសិទ្ធិនានាទាក់ទងនឹងនីតិវិធី និងដើម្បីដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវចំពោះការបង្កឱ្យមានការខូចខាតដល់បរិស្ថាន ។ វាជាការសំខាន់ណាស់ដែលសាធារណៈជនត្រូវមានមធ្យោបាយប្រកបដោយប្រសិទ្ធភាព ក្នុងការទទួលបាននូវនីតិវិធីទាំងផ្លូវការ និងក្រៅផ្លូវការ ដើម្បីដោះស្រាយវិវាទបរិស្ថានឱ្យបានឆាប់រហ័ស និងដោយយុត្តិធម៌ ។

## ៣.៤. គោលការណ៍ សមភាពយេនឌ័រនៅក្នុងការចូលរួមជាសាធារណៈ

ការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រី គឺត្រូវតែធ្វើការលើកកម្ពស់នៅក្នុងការសម្រេចចិត្តផ្នែកបរិស្ថាននៅគ្រប់កម្រិតទាំងអស់ ។ ការវាយតម្លៃហេតុប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍ និងផែនការគ្រប់គ្រងបរិ-ស្ថាន ត្រូវរួមបញ្ចូលនូវយន្តការនានា ដើម្បីវាយតម្លៃប្រកបដោយប្រសិទ្ធភាពនូវការប៉ះពាល់លើស្ត្រីខណៈពេលដែលកិច្ចដំណើរការនៃការចូលរួមជាសាធារណៈ នឹងត្រូវដាក់បញ្ចូលនូវយុទ្ធសាស្ត្រ ក្នុងការសម្របសម្រួល ការចូលរួមដ៏មានសារៈសំខាន់របស់ស្ត្រី ។

## ៣.៥. គោលការណ៍នៃការលើកកម្ពស់ជនជាតិដើមភាគតិចនៅក្នុងការចូលរួមជាសាធារណៈ

គោលការណ៍នេះទទួលស្គាល់ថា ជាទូទៅ ជនជាតិដើមភាគតិចទទួលរងការប៉ះពាល់ជាអវិជ្ជមានពីគម្រោងអភិវឌ្ឍន៍ និងត្រូវការនូវការការពារជាពិសេស ។ ការចូលរួមជាសាធារណៈជាមួយសហគមន៍ជន

ជាតិដើមភាគតិច ត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន និងដោយមានការពិចារណាត្រឹមត្រូវលើស្ថានភាពដែលងាយរងគ្រោះរបស់ពួកគេ ។ ស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (២០០៩) ទស្សនៈ និងសេចក្តីកង្វល់របស់ជនជាតិដើមភាគតិច ត្រូវយកមកគិតគូរ នៅពេលធ្វើការពិចារណាអំពីគម្រោងនានាដែលអាចនាំឱ្យមានការប៉ះពាល់ដល់ជនជាតិដើមភាគតិច ។

## ៣.៦. គោលការណ៍ផ្សេងៗទៀត

- គោលការណ៍រួបរួមគ្រប់អ្នកពាក់ព័ន្ធទាំងអស់ គឺជាគោលការណ៍ ដើម្បីលើកកម្ពស់នូវការកសាងនូវការមូលមតិជាឯកច្ឆន្ទ និងការព្រមព្រៀងរវាង អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ។
- គោលការណ៍បើកទូលាយ និងតម្លាភាព គ្រប់ដំណាក់កាល និងសកម្មភាព គឺជាគោលការណ៍ដើម្បីធានាថា កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺត្រូវស្ថិតក្រោមការពិនិត្យពិច័យរបស់សាធារណៈជន និងធានាថា សេចក្តីសម្រេចចិត្តត្រូវធ្វើឡើងស្របទៅតាមនីតិវិធីដែលពាក់ព័ន្ធនានា ។
- គោលការណ៍ភាពត្រឹមត្រូវ គឺជាគោលការណ៍នៃការចៀសវាងពីដំណើរការណាមួយ ដែលអាចនាំទៅកាន់ការអនុវត្តមិនត្រឹមត្រូវ ឬ អំពើពុករលួយ ។ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរតែមានភាពត្រឹមត្រូវ និងសមនឹងទទួលបាននូវទំនុកចិត្ត និងភាពជឿជាក់ ។
- គោលការណ៍ឆ្លើយតបទៅនឹងជាតុចូល និងតម្រូវការរបស់អ្នកពាក់ព័ន្ធ គឺជាគោលការណ៍ដែលថា ក្តីបារម្ភ និងទស្សនៈរបស់អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវទទួលបាននូវគុណតម្លៃ និងទទួលយកទៅពិចារណាដោយពិតប្រាកដ ។ ប្រសិនបើសេចក្តីកង្វល់ទាំងនេះមិនទទួលបានការគាំទ្រនោះទេ នោះគេត្រូវផ្តល់ហេតុផលសមរម្យទៅដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។
- គោលការណ៍នៃភាពជឿជាក់ ការពង្រឹងភាពជឿជាក់ និងទំនុកចិត្តរបស់អ្នកពាក់ព័ន្ធ គឺជាគោលការណ៍ដែលថា កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាការកសាងភាពជឿជាក់នៅក្នុងកិច្ចដំណើរការទាំងមូល ។ គម្រោង ឬសកម្មភាព ដែលបានស្នើឡើងនីមួយៗដែលត្រូវស្ថិតក្រោមកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែត្រូវបានប្រើប្រាស់ដើម្បីពង្រឹងនូវកិច្ចដំណើរការទាំងមូល ។

## ៤. និយមន័យ

**ជម្រើស៖** ទាក់ទងនឹងគម្រោងមួយដែលបានស្នើឡើង នឹងដាក់បញ្ចូលនូវការវាយតម្លៃអំពីជម្រើសដែលមានការប៉ះពាល់កម្រិតទាប ចំពោះ៖

- ទ្រព្យសម្បត្តិ ឬទីតាំងដែលត្រូវបានស្នើឡើង ដើម្បីអនុវត្តគម្រោង
- ប្រភេទនៃគម្រោងដែលត្រូវអនុវត្ត
- ការរចនា ឬគំនូសប្លង់នៃគម្រោង
- បច្ចេកវិជ្ជា ដែលត្រូវប្រើប្រាស់នៅក្នុងគម្រោង
- ទិដ្ឋភាពប្រតិបត្តិការនៃគម្រោង និង
- ចរិកលក្ខណៈ ឬទិដ្ឋភាពដ៏សំខាន់ដទៃទៀតនៃគម្រោង ដែលត្រូវចាត់ទុកថាសមរម្យ ដោយក្រសួង ។

**បរិស្ថាន៖** សំណាញ់ដ៏ស្មុគ្រស្មាញនៃអន្តរទំនាក់ទំនងរវាងសមាសភាគ ដែលមានជីវិត និងគ្មានជីវិត ដែលទ្រទ្រង់ជីវិតទាំងអស់នៅលើផែនដី រួមបញ្ចូល ទិដ្ឋភាពសង្គម/សុខភាព នៃអត្ថិភាពនៃមនុស្សជាតិ ។ សមាសភាគផ្នែករូបសាស្ត្រ ជីវសាស្ត្រ សង្គម សាសនា និងវប្បធម៌ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងមានឥទ្ធិពលលើការរីកចម្រើន និងការអភិវឌ្ឍន៍នៃសារពាង្គកាយមានជីវិត ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖** គឺជាការវាយតម្លៃយ៉ាងលម្អិត អំពីរូបសាស្ត្រ ជីវៈសាស្ត្របរិស្ថានសេដ្ឋកិច្ច-សង្គម និងធនធាននានា ដោយផ្អែកជាចម្បងទៅលើទិន្នន័យដែលប្រមូលបាន/ទិន្នន័យចម្បង (Primary Data) ចំពោះតំបន់ ដែលស្ថិតនៅក្នុង ឬនៅជុំវិញទីតាំងគម្រោង ។ វាបង្កើតនូវមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណ ការព្យាករណ៍ និងការវិភាគអំពីការប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមានឡើងលើបរិស្ថាន និងសង្គម ដោយសារសកម្មភាពគម្រោង ក្នុងគោលបំណងកំណត់អំពីវិធានការក្នុងការកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមាន និងបង្កើនជាអតិបរមានូវផលប៉ះពាល់វិជ្ជមាន ។

**ផែនការគ្រប់គ្រងបរិស្ថាន៖** គឺជាផែនការសម្រាប់ការគ្រប់គ្រងបរិស្ថាន ដូចមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលរៀបចំដោយម្ចាស់គម្រោង និងឯកភាពដោយក្រសួងបរិស្ថាន ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង៖** គឺជាការវាយតម្លៃជាបឋម និងជាចម្បងទៅលើ ទិន្នន័យដែលមានស្រាប់/ទិន្នន័យបន្ទាប់បន្សំ (Secondary Data) នៃរូបសាស្ត្រ ជីវៈសាស្ត្រ បរិស្ថានសេដ្ឋកិច្ចសង្គម និងធនធាននានា ចំពោះតំបន់ដែលស្ថិតនៅក្នុង ឬនៅជុំវិញទីតាំងគម្រោង ។ វាបង្កើតនូវមូលដ្ឋាន

សម្រាប់ការកំណត់អត្តសញ្ញាណ ការព្យាករណ៍ និងការវិភាគអំពីផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមានឡើងលើបរិស្ថាន និងសង្គម ដោយសារសកម្មភាពគម្រោង ក្នុងគោលបំណងកំណត់អំពីវិធានការក្នុងការកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមាន និងបង្កើនជាអតិបរមានូវផលប៉ះពាល់វិជ្ជមាន ។

**សាធារណៈ ៖** គឺជាសហគមន៍ទូទៅ ដែលរួមបញ្ចូល អ្នកពាក់ព័ន្ធទាំងអស់ និងអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ។

**ការចូលរួមជាសាធារណៈ** ៖ គឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ ដែលទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ រួមបញ្ចូល ក្រសួង/ស្ថាប័ន អាជ្ញាធរមូលដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា អ្នកតំណាងរបស់ប្រជាពលរដ្ឋដែលរងការប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាល ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ដែលមានការចាប់អារម្មណ៍ (ផលប្រយោជន៍) នៅក្នុងតំបន់គម្រោង ឬ គម្រោងដែលបានស្នើឡើង ។

**ប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ពីគម្រោង** ៖ គឺជារូបវន្តបុគ្គល នីតិបុគ្គល ឬអង្គការនានា ដែលទទួលរងការប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ពីគម្រោងវិនិយោគ (ឬដែលទំនងជានឹងទទួលរងការប៉ះពាល់) ដោយសារតែមានការស្នើដោយស្របច្បាប់ ក្នុងការកាន់កាប់ដី ឬអចលនទ្រព្យ ការផ្លាស់ប្តូរនៃប្រភេទដី និងផលប៉ះពាល់លើប្រព័ន្ធបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់តាំងទីលំនៅរបស់ពួកគេ ។ វាអាចរួមបញ្ចូលក្រុមមនុស្សដែលងាយរងគ្រោះ និងជនជាតិដើមភាគតិច ដែលត្រូវការនូវការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា កង្វល់របស់ពួកគេត្រូវបានដោះស្រាយ ។

**ការកំណត់វិសាលភាពគម្រោង** ៖ គឺជាដំណើរការក្នុងការកំណត់នូវិសាលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬដំបូង និងទិន្នន័យដែលត្រូវការប្រមូល និងវិភាគ ដើម្បីវាយតម្លៃនូវការប៉ះពាល់នៃគម្រោងវិនិយោគទៅលើបរិស្ថាន ដែលក្នុងនោះ ការសិក្សាបែបនេះតម្រូវឱ្យមានលក្ខខណ្ឌការងារ ដើម្បី រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**ការធ្វើចំណាត់ថ្នាក់គម្រោង** ៖ គឺជាដំណាក់កាលនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលកំណត់ថា តើគម្រោងដែលបានស្នើឡើង ឬសកម្មភាពណាមួយ តម្រូវឱ្យមាននូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬទម្រង់ដទៃទៀតនៃការវាយតម្លៃបរិស្ថាន ឬការឯកភាព ។

**អ្នកពាក់ព័ន្ធ** ៖ គឺជាបុគ្គល ឬក្រុម ឬសហគមន៍ ដែលស្ថិតនៅក្រៅពីប្រតិបត្តិការស្នូលនៃគម្រោង ដែលអាចទទួលរងការប៉ះពាល់ពីគម្រោង ឬដែលមានការចាប់អារម្មណ៍ (ផលប្រយោជន៍) នៅក្នុងគម្រោងនោះ ។ អ្នកពាក់ព័ន្ធអាចរួមបញ្ចូល បុគ្គល ធុរៈកិច្ច អ្នកសិក្សា សហគមន៍ និង រដ្ឋបាលមូលដ្ឋាន ។ អ្នកពាក់ព័ន្ធអាចរួមបញ្ចូល ក្រសួងដទៃទៀត ក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បណ្តាញសារ

ព័ត៌មាន និងប្រជាពលរដ្ឋដែលមានកង្វល់អំពីគម្រោង ដែលប្រហែលជាមិនរស់នៅក្នុងតំបន់ដែលទទួលរងការប៉ះពាល់ដោយផ្ទាល់ពីគម្រោងនោះទេ ។

**លក្ខខណ្ឌការងារ** ៖ គឺជាការពិពណ៌នាអំពីការងារទាំងអស់ ដែលត្រូវធ្វើ នៅពេលអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ស្របទៅតាមវិសាលភាពនៃការសិក្សា ដើម្បីវាយតម្លៃការប៉ះពាល់ដល់បរិស្ថាន ។

## ៥. ដំណាក់កាលនានានៃការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមមាន ដំណាក់កាលផ្សេងៗគ្នាមួយចំនួន ។ ដំណាក់កាលទាំងនេះមានលក្ខណៈឯករាជ្យ ប៉ុន្តែផ្សាភ្ជាប់គ្នា ដើម្បីបំពេញនីតិវិធីឱ្យបានពេញលេញ ។ គោលការណ៍នេះ គិតគូដោះស្រាយអំពីការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលនីមួយៗ នៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមបញ្ចូលនូវដំណាក់កាលមួយចំនួន ដែលត្រូវបានទទួលស្គាល់ថាជាដំណាក់កាលដែលការចូលរួមជាសាធារណៈគួរតែត្រូវធ្វើឡើង ដូចខាងក្រោម៖

1. ដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោង
2. ដំណាក់កាលកំណត់វិសាលភាពគម្រោង
3. ដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិ-ស្ថាន
4. ដំណាក់កាលត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
5. ដំណាក់កាលឯកភាព ឬបដិសេធ ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
6. ដំណាក់កាលសាងសង់ ប្រតិបត្តិការ និងការអង្កេតតាមដានគម្រោង និងការអនុលោមតាមច្បាប់ ។

ការចូលរួមជាសាធារណៈនេះ មានគោលដៅក្នុងការផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធនានា ក្នុងការចូលរួម និងបង្ហាញពីមតិយោបល់ និងការព្រួយបារម្ភរបស់គេទៅលើគម្រោងអភិវឌ្ឍសាធារណៈ និងឯកជនព្រមទាំងជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យសាធារណៈ វិស័យឯកជន និងសាធារណជន

ទូទៅ លើគម្រោងអភិវឌ្ឍន៍ ។ ការចូលរួមជាសាធារណៈអាចកសាងទំនុកចិត្ត និងការគាំទ្រ សម្រាប់ទាំងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសម្រាប់សកម្មភាព ឬការអភិវឌ្ឍន៍ជាក់លាក់ណាមួយ ។

## ៦. កម្រិតនៃការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការចូលរួមជាសាធារណៈអាចកើតឡើងនៅក្នុងកម្រិតផ្សេងៗគ្នា នៃការចូលរួមផ្ទាល់ និងការប្រាស្រ័យទាក់ទង ។ ការចូលរួមជាសាធារណៈនេះត្រូវបានហៅថា កម្រិតនៃការចូលរួមជាសាធារណៈ ។ វាចាប់ផ្តើមនៅកម្រិតដ៏សាមញ្ញបំផុតនៃការជូនដំណឹង (ការផ្តល់ពត៌មាន) ទៅដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ។ កម្រិតចំនួនពីរបន្ទាប់ទៀត ដែលរួមមាន "ការពិគ្រោះយោបល់" និង "ការចូលរួមដោយផ្ទាល់" មានការចូលរួមច្រើនជាងពីសំណាក់ អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។ ការចូលរួមជាសាធារណៈនេះអាចមានទម្រង់ជាច្រើន ប៉ុន្តែវាគឺជាផ្នែកមួយនៃការបង្កើតឡើងនូវមតិយោបល់ត្រឡប់ដ៏ច្រើនជាងមុនទៅកាន់ម្ចាស់គម្រោង ។ នៅចំណុចខ្ពស់បំផុតនៃកម្រិតនៃការចូលរួមជាសាធារណៈ គឺ "កិច្ចសហការ" និង "ការផ្តល់អំណាច" ។ នៅកម្រិតទាំងពីរនេះ នៃការចូលរួមជាសាធារណៈ អ្នកទទួលរងការប៉ះពាល់ពីគម្រោង មានការចូលរួមផ្ទាល់កម្រិតខ្ពស់ នៅក្នុងដំណើរការនេះ ដែលត្រូវក្លាយជាដៃគូ និងមានលក្ខណៈស្មើគ្នានឹងម្ចាស់គម្រោង ។ "ការផ្តល់អំណាច" គឺជាទម្រង់ខ្ពស់បំផុតនៃការចូលរួមជាសាធារណៈ ។ នេះគឺជាចំណុចដែលអ្នកទទួលរងការប៉ះពាល់ពីគម្រោងអាចក្លាយជាអ្នកធ្វើការសម្រេចចិត្តលើគម្រោង ហើយប្រសិនបើគម្រោងនោះ ខ្វះនូវការគាំទ្រពីអ្នករងការប៉ះពាល់ពីគម្រោង ពេលនោះគម្រោងនោះមិនអាចបន្តដំណើរការទៅមុខទៀតបានឡើយ ។ ឧទាហរណ៍ នៅក្រោមគោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សហគមន៍ជនជាតិដើមភាគតិច ទទួលបាននូវអំណាច ក្នុងការឯកភាព ឬបដិសេធ ចំពោះសំណើចុងក្រោយនៃគម្រោង ។

IAP2 Spectrum of Public Participation

International Association for Public Participation

*Increasing Level of Public Impact* →

| | Inform | Consult | Involve | Collaborate | Empower |
|---|---|---|---|---|---|
| Public participation goal | To provide the public with balanced and objective information to assist them in understanding the problem, alternatives, opportunities and/or solutions. | To obtain public feedback on analysis, alternatives and/or decisions. | To work directly with the public throughout the process to ensure that public concerns and aspirations are consistently understood and considered. | To partner with the public in each aspect of the decision including the development of alternatives and the identification of the preferred solution. | To place final decision-making in the hands of the public. |
| Promise to the public | We will keep you informed. | We will keep you informed, listen to and acknowledge concerns and aspirations, and provide feedback on how public input influenced the decision. | We will work with you to ensure that your concerns and aspirations are directly reflected in the alternatives developed and provide feedback on how public input influenced the decision. | We will look to you for advice and innovation in formulating solutions and incorporate your advice and recommendations into the decisions to the maximum extent possible. | We will implement what you decide. |

## ៦.១. ការជូនដំណឹង

កម្រិតនៃការជូនដំណឹងនៃការចូលរួមជាសាធារណៈ មិនផ្តល់ឱកាសជាក់លាក់ណាមួយសម្រាប់អ្នកពាក់ព័ន្ធទាំងអស់នោះទេ ប៉ុន្តែវាផ្តល់ឱ្យសាធារណជននូវព័ត៌មាន ដែលពួកគេត្រូវការដឹងឮ និងកិច្ចដំណើរការនៃស្ថាប័នធ្វើសេចក្តីសម្រេច ។

ទាំងគោលដៅ និងការសន្យានៅក្នុងកម្រិតនៃការជូនដំណឹងនេះ គឺជាការរក្សាទុកជាព័ត៌មានតែប៉ុណ្ណោះ។

ការជូនដំណឹងដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត គឺជាដំណាក់កាលដំបូង ក្នុងការធានាថា អាចមានការចូលរួមជាសាធារណៈសមរម្យ នៅក្នុងកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

## ៦.២. ការពិគ្រោះយោបល់

កម្រិតនៃការពិគ្រោះយោបល់នៃការចូលរួមជាសាធារណៈគឺជាឱកាសមូលដ្ឋានអប្បបរមាសម្រាប់ជាតុចូលរបស់សាធារណជនដាក់ចូលទៅក្នុងការសម្រេចចិត្ត ។ ការពិគ្រោះយោបល់មានន័យជាការសួរ និងការឆ្លើយសំណួរ ។

គោលដៅនៃការចូលរួមជាសាធារណៈក្នុងកម្រិតពិគ្រោះយោបល់ គឺការទទួល និងពិចារណាលើជាតុចូលរបស់សាធារណជន ។ ការសន្យានៅកម្រិតពិគ្រោះយោបល់នេះគឺត្រូវពិចារណាលើជាតុចូលរបស់សាធារណជនដែលត្រូវទទួលនិងត្រូវផ្តល់ត្រឡប់មកវិញ ដូចជា តើជាតុចូលទាំងនោះត្រូវបញ្ចូល ទៅក្នុងការសម្រេចចិត្តគម្រោងឬទេ?

## ៦.៣. ការចូលរួមផ្ទាល់

កម្រិតនៃការចូលរួមផ្ទាល់នៅក្នុងការចូលរួមជាសាធារណៈ គឺមានកម្រិតខ្ពស់ជាងការពិគ្រោះយោបល់ ។ ការចូលរួមផ្ទាល់មានន័យថាត្រូវតែបញ្ចូលជាតុចូលដែលបានផ្តល់ជូន។ កម្រិតការចូលរួមផ្ទាល់គឺ សាធារណជនត្រូវបានអញ្ជើញឱ្យចូលរួមក្នុងដំណើរការចាប់ពីដំបូង និងត្រូវបានផ្តល់ឱកាសជាច្រើនរាប់ទាំងដំណាក់កាលនៃកិច្ចដំណើរការនៅក្នុងការធ្វើសេចក្តីសម្រេច ។

គោលដៅនៃការចូលរួមជាសាធារណៈនៅកម្រិតការចូលរួមផ្ទាល់ គឺធ្វើការជាមួយគ្នាផ្ទាល់ជាមួយសាធារណៈ និងពិចារណាលើជាតុចូលរបស់ពួកគេតាមរយៈកិច្ចដំណើរការនៃការសម្រេចចិត្ត។

ការសន្យានៅកម្រិតនៃការចូលរួមផ្ទាល់នេះ មានន័យថា មតិយោបល់ដែលទទួលបានមកពីអ្នកទទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត នឹងទទួលបាននូវការឆ្លើយតប ។ វាគឺជាកម្រិតមួយដែលផ្តល់ឱ្យអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀតនូវមតិយោបល់ត្រឡប់ស្តីពីរបៀបដែលបញ្ហានានារបស់ពួកគេត្រូវបានយកទៅពិចារណា និងពីរបៀបដែលគម្រោងនោះត្រូវបានកែសម្រួល ដើម្បីឆ្លើយតបចំពោះការព្រួយបារម្ភ ។

## ៦.៤. កិច្ចសហការ

កម្រិតនៃកិច្ចសហការនៃការចូលរួមជាសាធារណៈ រួមបញ្ចូលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ នៅដំណាក់កាលនេះ អ្នកទទួលរងផលប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀតផ្តល់ធាតុចូលដោយផ្ទាល់ក្នុងការធ្វើការសម្រេចចិត្ត ។ កិច្ចសហការជានិច្ចកាលលើកកម្ពស់អ្នកពាក់ព័ន្ធនានា ដើម្បីឯកភាពលើដំណោះស្រាយរួម ។ កម្រិតនៃការចូលរួមនេះអាចត្រូវបានបង្ហាញនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលរៀបចំឡើងដោយម្ចាស់គម្រោង ។

ការសន្យានៅកម្រិតនេះគឺសាធារណជននឹងត្រូវបញ្ចូលសកម្មភាពសំខាន់ៗ ការសម្រេចចិត្តទាំងអស់ ព្រមទាំងធាតុចូលរបស់ពួកគេ នឹងត្រូវបានដាក់បញ្ចូលគ្នាឱ្យបានច្រើនជាអតិបរមា ។

## ៦.៥. ការផ្តល់អំណាច

កម្រិតនៃការផ្តល់អំណាចនៃការចូលរួមជាសាធារណៈ មានន័យថា ស្ថាប័នសាធារណៈផ្តល់ជូនអ្នកទទួលរងផលប៉ះពាល់ពីគម្រោងនូវឱកាសក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ។

ការសន្យានៅដំណាក់កាលនេះ គឺស្ថាប័នសាធារណៈនឹងអនុវត្តនូវអ្វីដែលអ្នកទទួលរងផលប៉ះពាល់ពីគម្រោងបានធ្វើការសម្រេចចិត្ត ។

តារាងទី ១៖ សេចក្តីសង្ខេបនៃកម្រិតនៃការចូលរួមជាសាធារណៈដែលត្រូវបានរំពឹងទុកនៅក្នុងដំណាក់កាលនីមួយៗនៃ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្រោមគោលការណ៍ណែនាំនេះ

| ដំណាក់កាលនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | កម្រិតនៃការចូលរួមជាសាធារណៈដែលត្រូវបានរំពឹងទុក |
|---|---|
| ១- ការធ្វើចំណាត់ថ្នាក់គម្រោង | ការជូនដំណឹង (អប្បបរមា) |
| ២- ការកំណត់វិសាលភាពគម្រោង | ការពិគ្រោះយោបល់ (អប្បបរមា) |
| ៣- ការសិក្សាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ការពិគ្រោះយោបល់ និងការចូលរួមផ្ទាល់ (អប្បបរមា) |
| ៤- ការត្រួតពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន | ការពិគ្រោះយោបល់ (អប្បបរមា) |

| | |
|---|---|
| ៥- ការធ្វើការសម្រេចចិត្តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន | ការជូនដំណឹង (អប្បបរមា) |
| ៦- ការសាងសង់ ប្រតិបត្តិការ ការអង្កេតតាមដាន និងការអនុលោម | ចំណុចណាមួយនៃកម្រិតនៃការចូលរួម អាស្រ័យលើគម្រោង (គម្រោងអាទិភាព)<br><br>ស្របតាមផែនការគ្រប់គ្រងបរិស្ថាន និងការប្ដេជ្ញានៃម្ចាស់គម្រោង |

## ៧. ការទទួលបានព័ត៌មាននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព័ត៌មាន និងទិន្នន័យជាច្រើននឹងត្រូវបានបង្កើត និងប្រមូលដោយម្ចាស់គម្រោង ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត ។ ការចូលរួមជាសាធារណៈពិតប្រាកដ និងមានប្រសិទ្ធភាព គឺពឹងផ្អែកលើ អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀតមានលទ្ធភាពទទួលបានព័ត៌មានពាក់ព័ន្ធ ។ ព័ត៌មានទាំងនេះ ត្រូវតែអាចស្វែងរកបាន ដោយងាយស្រួល (រួមបញ្ចូល តាមរយៈអ៊ិនធឺណិត និងឯកសារថតចម្លង) និងជាភាសា និងការប្រើប្រាស់ពាក្យពេចន៍ ដែលងាយយល់ ។

ម្ចាស់គម្រោង និង ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែផ្ដល់ព័ត៌មានចាប់តាំងពីដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោង រហូតដល់ដំណាក់កាលឯកភាពលើគម្រោង ដោយក្រសួង ។ ការផ្ដល់ព័ត៌មាននេះគួរតែមានលក្ខណៈបន្តជានិរន្តរ៍ ដើម្បីធានាថា អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត អាចទទួលបានព័ត៌មានពាក់ព័ន្ធ ដើម្បីអាចចូលរួមដោយមានប្រសិទ្ធភាព ។

នៅពេលគម្រោងទទួលបានការឯកភាព ម្ចាស់គម្រោង និងអ្នកម៉ៅការ និងអ្នកម៉ៅការបន្តរបស់ខ្លួន ត្រូវទទួលខុសត្រូវក្នុងការផ្ដល់ព័ត៌មានឱ្យបានទាន់ពេលវេលា និងក្នុងលក្ខណៈជាបន្តបន្ទាប់ ទៅកាន់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។ នៅពេលដែលគម្រោងចាប់ផ្ដើមប្រតិបត្តិការ ម្ចាស់គម្រោង និងប្រតិបត្តិករ តម្រូវឱ្យបន្តផ្ដល់នូវព័ត៌មានសមរម្យទៅកាន់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត រួមបញ្ចូល រដ្ឋាភិបាល ។

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានតម្រូវឱ្យម្ចាស់គម្រោង ឬទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រៀបចំកិច្ចប្រជុំជាមួយប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ពីគម្រោង ។ កិច្ចប្រជុំនេះត្រូវធ្វើឡើងនៅក្នុងលក្ខណៈមួយដែលបង្កើននូវឱកាសសម្រាប់ការចូលរួមពាក់ព័ន្ធ ។ ប្រសិនបើព័ត៌មាន មានលក្ខណៈបច្ចេកទេស ពេលនោះត្រូវមានអ្នកជំនាញការ ដែលអាចជួយពន្យល់ទៅដល់អ្នកទទួលរងការប៉ះ

ពាល់ពីគម្រោង ។ ប្រសិនបើអ្នកទទួលរងការប៉ះពាល់ពីគម្រោងត្រូវការនូវជំនួយផ្នែកភាសា ពេលនោះគេត្រូវផ្តល់ជំនួយនេះដល់ពួកគាត់ផងដែរ ។

# ជំពូក ២:

# និដ្ឋភាពច្បាប់

## ១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

**មាត្រា ៦៖**

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ បែបបទនៃកិច្ចដំណើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមដំណើររបស់ក្រសួងបរិស្ថាន។

ប្រភេទ និងទំហំគំរោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងបរិស្ថាន។

**មាត្រា ៧៖**

ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៦៖**

ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឲមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រប់ធនធានធម្មជាតិ។

**មាត្រា ១៧៖**

បែបបទនៃការចូលរួមរបស់សាធារណជន និងការស្រង់យកពត៌មានក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងបរិស្ថាន។

**មាត្រា ១៨៖**

ពត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមក រវាងក្រសួងបរិស្ថាន និងក្រសួងនានា។

## ២. អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩

**មាត្រា ១៖**

អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច
- កំណត់ប្រភេទ និងទំហំគំរោងសកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឲ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគំរោង។

## ៣.ប្រកាសស្តីពីស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩

| |
|---|
| **ប្រការ ១៖** |
| ប្រកាសនេះមានគោលបំណងអនុវត្តគោលការណ៍ណែនាំទូទៅស្តីពីការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពេញលេញ និងតារាងសង្ខេប មានដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និង ២ នៃប្រកាសនេះ។ |

| |
|---|
| **ប្រការ ៧៖** |
| នាយកដ្ឋានសង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគំរោង ដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើ ដើម្បីកំណត់ឲបានច្បាស់លាស់ថា គំរោងនេះគួរតំរូវឲ្យរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។ |

| |
|---|
| **ប្រការ ៩៖** |
| នាយកដ្ឋានសង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដោយអនុវត្តទៅតាមគោលការណ៍ណែនាំទូទៅនេះ។ |

| |
|---|
| **ប្រការ ១៤៖** |
| នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចតាមដាន ឃ្លាំមើល និងចាត់វិធានការឲម្ចាស់គំរោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាននៅក្នុង |

ដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងនៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តបានឯកភាព ។

## ៤. សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព និងភារៈកិច្ច ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**ប្រការ ២៖**

ក្រុមការងារ សម្របសម្រួលការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានភារៈកិច្ចដូចតទៅ៖

- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុងក្រុមការងារសម្របសម្រួលការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់គម្រោងដែលស្នើឡើង និងសកម្មភាពអភិវឌ្ឍន៍នានារបស់ឯកជន ឬសាធារណៈ ដែលមានស្រាប់ និងកំពុងដំណើរការ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់បឋម របស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- សម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង
- រាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងបរិស្ថាន អំពីលទ្ធផលនៃកិច្ចប្រជុំផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

# ជំពូក ៣:

# នីតិវិធីនៃការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ១. កម្រិត និងទម្រង់នៃការចូលរួមជាសាធារណៈ

### ១.១. ការកំណត់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត

ដំណាក់កាលទី១គឺត្រូវកំណត់អត្តសញ្ញាណអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។ ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែព្យាយាមយកចិត្តទុកដាក់ក្នុងការកំណត់ និងធានាឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងក្នុង និងក្រៅរដ្ឋាភិបាល ដែលអាចទទួលរងការប៉ះពាល់ និងមានចំណាប់អារម្មណ៍លើគម្រោង និងសក្តានុពលនៃការប៉ះពាល់ ។ វិសាលភាពភូមិសាស្ត្រគួរតែបញ្ចូលតំបន់ដែលស្ថិតនៅក្នុង និងជុំវិញគម្រោងទាំងព្រំប្រទល់នយោបាយ និងព្រំប្រទល់ធនធានធម្មជាតិ ឬហៅបានថាវិសាលភាពភូមិសាស្ត្រទាំងស្រុងនៃធនធានមនុស្ស និងធម្មជាតិដែលទទួលរងការប៉ះពាល់ពីសកម្មភាពនៃគម្រោងដែលស្នើសុំ។ ការប៉ះពាល់នៃគម្រោងអាចជាការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ។

ការកំណត់អំពីបញ្ហាជាក់លាក់ដែលបានបង្ហាញដោយគម្រោង ឬកម្មវិធីស្នើសុំ នឹងជួយកំណត់អត្តសញ្ញាណនៃអ្នកទទួលរងការប៉ះពាល់សំខាន់ៗ និងអ្នកពាក់ព័ន្ធដទៃទៀត ហើយអ្នកពាក់ព័ន្ធទាំងនោះនឹងជួយកំណត់ពីបញ្ហាសម្រាប់វិភាគផងដែរ ។ អ្នកពាក់ព័ន្ធបន្ថែមទៀតនឹងត្រូវបានកំណត់ជាបន្តបន្ទាប់តាមរយៈដំណើរការវាយតម្លៃទាំងមូល និងគួរតែដាក់បញ្ចូលនៅក្នុងសកម្មភាពចូលរួមជាមួយសាធារណៈបន្ទាប់ទៀត ។ ការចូលរួមពីសាធារណជនគួរតែបញ្ចូលរាល់អ្នកចាប់អារម្មណ៍នឹងគម្រោងនានា ដូចជា អ្នកដែលចាប់អារម្មណ៍នឹងគោលនយោបាយគម្រោងដែលពាក់ព័ន្ធនៅប្រទេសកម្ពុជា សហគមន៍ដែលរស់នៅផ្នែកខាងក្រោម និងខាងលើនៃទីតាំងស្នើសុំ ឬអ្នកដែលមានសក្តានុពលរងការប៉ះពាល់ពីគម្រោងអភិវឌ្ឍ និងអ្នកប្រើប្រាស់ដីដែលអាចរងការប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍។

ការកំណត់អត្តសញ្ញាណនៃអ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ជាលក្ខណៈប្រព័ន្ធ និងជាលក្ខណៈបរិយាប័ន គឺជាចំណុចគន្លឹះដ៏សំខាន់នៃដំណាក់កាលកំណត់វិសាលភាពគម្រោង ។ វាគឺជាការចាំបាច់ណាស់ក្នុងការរៀបចំផែនការនៃការចូលរួមជាសាធារណៈ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍នៃការកំណត់វិសាលភាពគម្រោង ។ ផែនការនៃការចូលរួមជាសាធារណៈ នឹងគូសបង្ហាញអំពីដំណាក់កាល (ដំហាន) ដែលត្រូវអនុវត្ត និងព័ត៌មានដែលត្រូវផ្តល់ឱ្យ នៅក្នុងអំឡុងពេលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ផែនការនៃការចូលរួមជាសាធារណៈ គួរតែផ្តល់នូវព័ត៌មានលម្អិតអំពីរបៀបក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកតំណាងនៃអ្នកពាក់ព័ន្ធដទៃទៀត ។

**១. អ្នកទទួលរងការប៉ះពាល់ពីគម្រោង**

- ម្ចាស់ដី និងអ្នកតាំងលំនៅអចិន្ត្រៃយ៍ ទាំងអ្នកមូលដ្ឋាន និងអ្នកនៅក្រោមខ្សែទឹក
- ក្រុមជនជាតិដើមភាគតិច នៅក្នុងតំបន់ដែលទទួលរងការប៉ះពាល់
- ស្ត្រី កុមារ និងមនុស្សចាស់
- ក្រុមងាយរងគ្រោះ រួមបញ្ចូលជនពិការ និងជនក្រីក្រ

**២. អាជ្ញាធររដ្ឋាភិបាល**

- អាជ្ញាធរថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន
- អាជ្ញាធរទទួលខុសត្រូវចំពោះការត្រួតពិនិត្យការបំពុល រួមបញ្ចូល ការបំពុលទឹក សំណល់ ដី សំឡេង និងការបំពុលខ្យល់ ។
- អាជ្ញាធរទទួលខុសត្រូវចំពោះការការពារធម្មជាតិ បេតិកភ័ណ្ឌវប្បធម៌ និងទេសភាព
- អាជ្ញាធរសុខភាព និងសុវត្ថិភាព
- អាជ្ញាធរត្រួតពិនិត្យការប្រើប្រាស់ដី អាជ្ញាធររៀបចំផែនការលំហ និងអាជ្ញាធររៀបចំតំបន់នានា
- អាជ្ញាធរនៅក្នុងប្រទេសជិតខាង ក្នុងករណីមានបញ្ហាទាក់ទងនឹងផលប៉ះពាល់ឆ្លងដែន

**៣. អ្នកពាក់ព័ន្ធដទៃទៀត**

- ក្រុមមនុស្សដែលមានការចាប់អារម្មណ៍ផ្នែកអភិវឌ្ឍន៍បរិស្ថាន និងសង្គម ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ

- នាយកដ្ឋាន តាមវិស័យ នៃក្រសួង-ស្ថានប័ន ដែលទទួលខុសត្រូវផ្នែកកសិកម្ម ថាមពល ព្រៃឈើ និងជលផល ។ល។ (ដែលផលប្រយោជន៍របស់ពួកគេអាចទទួលរងការប៉ះពាល់) ។
- ភ្នាក់ងារអន្តរជាតិ ដែលផលប្រយោជន៍របស់ពួកគេអាចទទួលរងការប៉ះពាល់ ។
- និយោជកមូលដ្ឋាន និងសមាគមធុរកិច្ច ដូចជា សភាពាណិជ្ជកម្ម សហគមពាណិជ្ជកម្ម ។ល។
- អង្គការ សង្គមស៊ីវិល ដូចជា អង្គការស្ត្រី ក្រុមនានា ក្រុមយុវជន ។ល។
- អង្គការនិយោជកនានា ដូចជា សហជិពពាណិជ្ជកម្ម ។
- ក្រុមនានាដែលតំណាងឱ្យអ្នកប្រើប្រាស់បរិស្ថាន ដូចជា កសិករ អ្នកនេសាទ ស្ត្រី ដែលប្រើប្រាស់ធនធានមូលដ្ឋានសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់ការងារពាណិជ្ជកម្ម ប្រតិបត្តិករផ្នែកទេសចរណ៍ វិទ្យាស្ថានស្រាវជ្រាវ មហាវិទ្យាល័យ និងមជ្ឈមណ្ឌលជំនាញឯកទេសផ្សេងទៀត ។
- បណ្តាញសារព័ត៌មានថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។
- បណ្តាញសារព័ត៌មានថ្នាក់មូលដ្ឋាន និងថ្នាកជាតិ ។

**៤. សហគមន៍ទូទៅ**

- អ្នកតំណាងដែលត្រូវជ្រើសរើសតាមការបោះឆ្នោត និងបុគ្គលសំខាន់ៗក្នុងសហគមន៍ ដូចជា អ្នកដឹកនាំសាសនា ឬគ្រូបង្រៀន
- ក្រុមសហគមន៍មូលដ្ឋាន ក្រុមតាំងលំនៅអចិន្ត្រៃយ៍ ។ល។
- សហគមន៍ផ្នែកវិទ្យាសាស្ត្រ
- សមាជិកជាទូទៅនៃសាធារណៈជនមូលដ្ឋាន និងសាធារណៈជនទូទៅ ។

## ១.២. លទ្ធផលនៃការចូលរួមជាសាធារណៈ

លទ្ធផលសំខាន់ៗ នៃកិច្ចដំណើរការនៃការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព នឹងជួយៈ

– កំណត់អត្តសញ្ញាណអ្នកទទួលរងការប៉ះពាល់ពីគម្រោង
– កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធដទៃទៀត

- លើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ព្រះរាជាណាចក្រកម្ពុជា
- កំណត់អត្តសញ្ញាណអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត
- ជូនដំណឹងដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង អំពីគម្រោងដែលបានស្នើសុំ និងការប៉ះពាល់របស់វា
- ប្រមូលធាតុចូល គំនិតយោបល់ និងសេចក្តីបារម្ភរបស់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធទាំងអស់
- ទទួលយកព័ត៌មាន និងគំនិតយោបល់របស់សាធារណៈជន នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ឆ្លើយតបទៅកាន់គំនិតយោបល់របស់សាធារណៈជននៅក្នុងការរចនាគម្រោង
- ធ្វើឱ្យមានការចូលរួមពីសាធារណៈជននៅក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោង
- ជួយរដ្ឋាភិបាលនៅក្នុងដំណើរការវាយតម្លៃ និងការធ្វើការសម្រេចចិត្ត
- ទទួលយកចំណេះដឹង និងប្រពៃណីរបស់សហគមន៍មូលដ្ឋាន ជាមូលដ្ឋានក្នុងការធ្វើការសម្រេចចិត្ត
- សម្របសម្រួល និងពិចារណាអំពីជម្រើសនានានៃវិធានការ និងការងារសម្រាប់ប្រជាពលរដ្ឋ
- ធានាថា ការប៉ះពាល់ជាអវិជ្ជមានចម្បងៗមិនត្រូវបានមើលរំលង និងបង្កើនផលប្រយោជន៍ឱ្យដល់កម្រិតអតិបរមា
- កាត់បន្ថយវិវាទ តាមរយៈការកំណត់អត្តសញ្ញាណ និងការបញ្ចៀស ឬ ការកាត់បន្ថយបញ្ហាបឋមៗ
- ផ្តល់ឱកាសដល់សាធារណៈជននៅក្នុងដំណាក់កាលនៃការរចនាគម្រោង នៅក្នុងវិធានការវិជ្ជមាន
- ធ្វើឱ្យប្រសើរឡើងនៅក្នុងលក្ខណៈមួយដែលការធ្វើការសម្រេចចិត្ត នឹងត្រូវធ្វើឡើងនៅក្នុងលក្ខណៈតម្លាភាព និងការទទួលខុសត្រូវ
- លើកកម្ពស់ទំនុកចិត្តពីសាធារណៈជននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## **១.៣. ការទទួលបានព័ត៌មាន**

នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ម្ចាស់គម្រោង ឬទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរបង្កើតគេហទំព័រមួយសម្រាប់ផ្តល់ព័ត៌មានអំពីគម្រោង ។ គេហ

ទំព័រនេះត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំនូវព័ត៌មានអំពីស្ថានភាពនៃគម្រោង សេចក្តីថតចម្លងនៃការឯកភាព, ផែនការ និងរបាយការណ៍ និងលិខិតអនុញ្ញាត ដែលត្រូវបានតម្រូវសម្រាប់គម្រោង ព្រមទាំងព័ត៌មានលម្អិតអំពីការត្រួតពិនិត្យ និងការធ្វើសវនកម្មលើការអនុលោមតាមច្បាប់នៃគម្រោង ។

ផែនការនៃការចូលរួមជាសាធារណៈ គួរដាក់បញ្ចូលនូវព័ត៌មានលម្អិតអំពីពេលវេលា និងរបៀបដែលទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងផ្តល់ព័ត៌មានទៅកាន់អ្នកទទួលរងផលប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត។ ផែនការនៃការចូលរួមជាសាធារណៈនេះអាចរួមបញ្ចូលផងដែរនូវ គេហទំព័រ ហ្វេសប៊ុករបស់គម្រោង រួមជាមួយនឹងសេចក្តីលម្អិតអំពីព័ត៌មានដែលត្រូវផ្តល់ឱ្យនៅកម្រិតឃុំ ។

ព័ត៌មានដែលទាក់ទងនឹងគម្រោងដែលបានស្នើឡើង គួរតែផ្តល់ទៅឱ្យអ្នកដែលទទួលរងផលប៉ះពាល់ពីគម្រោង ។

## ១.៤. ការកំណត់ពេលវេលានៃការចូលរួមជាសាធារណៈ

ការចូលរួមជាសាធារណៈគួរតែចាប់ផ្តើមតាំងពីដំបូងនៅក្នុងដំណាក់កាលសិក្សាអំពីបុរេលទ្ធភាពនៃគម្រោង ប្រសិនបើអាចធ្វើទៅបាន ។ នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការចូលរួមជាសាធារណៈចាប់ផ្តើមនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោង ។ ការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់ និងកំណត់វិសាលភាពគម្រោងគឺមានសារៈសំខាន់ខ្លាំងណាស់។ ប្រសិនបើធ្វើបានល្អ វាគឺជាមូលដ្ឋានដ៏រឹងមាំសម្រាប់កិច្ចដំណើរដទៃទៀតនៃការវាយតម្លៃហេតុហេតុប៉ះពាល់បរិស្ថាន។

អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ក៏ត្រូវទទួលបានផងដែរនូវពេលវេលាដើម្បីពិចារណាអំពីព័ត៌មានដែលពួកគេទទួលបានអំពីគម្រោងដែលបានស្នើឡើង ។ វាគឺជាការសមហេតុផលក្នុងការអនុញ្ញាតឱ្យមានពេលវេលា យ៉ាងហោចណាស់ មួយ ឬ ពីរ សប្តាហ៍ ដើម្បីពិចារណាព័ត៌មានអំពីគម្រោង ។

សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានាអាចត្រូវការពេលវេលារហូតដល់៤សប្តាហ៍ ដើម្បីមានលទ្ធភាពក្នុងការពិចារណាអំពីព័ត៌មានទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ទាំងនោះ ។ ការនេះមានន័យថា ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែផ្តល់ពេលវេលាគ្រប់គ្រាន់ រវាងការផ្តល់ព័ត៌មានទៅកាន់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ និងការស្នើសុំមតិយោបល់ ។

# ២. ដំណាក់កាលចំណាត់ថ្នាក់គម្រោង

## ២.១. វិធីសាស្ត្រ

ដំណាក់កាលធ្វើចំណាត់គម្រោងគឺត្រូវបានតម្រូវឱ្យមាន ដើម្បីកំណត់ថា តើគម្រោងណាមួយត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។ វាគឺជាសេចក្តីសម្រេចមួយដែលធ្វើឡើងដោយក្រសួងបរិស្ថាន បន្ទាប់ពីបានធ្វើការពិចារណាលើព័ត៌មានដែលផ្តល់ឱ្យដោយម្ចាស់គម្រោង ។

ម្ចាស់គម្រោងត្រូវផ្តល់ព័ត៌មានអំពីគម្រោងរបស់ខ្លួនដល់អ្នកពាក់ព័ន្ធ ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ និង/ឬ អាជ្ញាធរដែនដី និងអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងសហគមន៍របស់ពួកគេ ។ ការផ្តល់ព័ត៌មានអំពីគម្រោងនេះ គឺមានសារៈសំខាន់ក្នុងការផ្តល់យោបល់ដល់អ្នកពាក់ព័ន្ធ អំពីអត្ថិភាពនៃសំណើររបស់គម្រោង និងដើម្បីចាប់ផ្តើមប្រមូលទិន្នន័យ និងព័ត៌មាន ។ នៅក្នុងដំណាក់កាលនៃការធ្វើចំណាត់ថ្នាក់គម្រោង ប្រហែលជាមានតែព័ត៌មានទូទៅអំពីគម្រោងតែប៉ុណ្ណោះ ។ ការធ្វើចំណាត់ថ្នាក់គម្រោងគឺជាឱកាសលើកដំបូងរបស់ម្ចាស់គម្រោង ដើម្បីចាប់ផ្តើមកសាងទំនុកចិត្តជាមួយសហគមន៍ និងដើម្បីផ្តល់ព័ត៌មានទៅកាន់អ្នកទទួលរងការប៉ះពាល់បរិស្ថាន ។

ជាទូទៅ ការធ្វើចំណាត់ថ្នាក់គម្រោងនេះធ្វើឡើងជាទម្រង់ការប្រជុំខ្នាតតូច នៅក្នុងតំបន់គម្រោង ឬតំបន់ជុំវិញគម្រោង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ដូចជា អាជ្ញាធរមូលដ្ឋាន និងអ្នកទទួលរងការប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ ។ វាក៏អាចធ្វើឡើងតាមរយៈការចុះផ្សាយនៅក្នុងការសែតផងដែរ ។ វិសាលភាពនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលនៃការធ្វើចំណាត់ថ្នាក់គម្រោង៖

- បង្កើតទំនាក់ទំនងរវាងម្ចាស់គម្រោង និង ទាំងសហគមន៍មូលដ្ឋាន និងភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ
- ធ្វើឱ្យប្រាកដថា សហគមន៍មូលដ្ឋានមានការយល់ដឹងអំពីសំណើរបស់គម្រោង និងដំណើរការនៃការធ្វើចំណាត់ថ្នាក់គម្រោង
- ផ្តល់ដល់សហគមន៍មូលដ្ឋាននូវឱកាស ក្នុងការចូលរួមចំណែកផ្តល់នូវទស្សនៈដំបូងរបស់ពួកគេទៅលើសំណើរបស់គម្រោង សម្រាប់ការពិចារណា នៅក្នុងការសម្រេចចិត្តក្នុងការធ្វើចំណាត់ថ្នាក់គម្រោង ។
- ធ្វើឱ្យប្រាកដថា សេចក្តីសម្រេចចិត្តក្នុងការធ្វើចំណាត់ថ្នាក់គម្រោង ត្រូវបានដាក់ឱ្យសាធារណៈជនអាចស្វែងរកបាន ។

## ២.២. រយៈពេល

យ៉ាងហោចណាស់ កិច្ចប្រជុំចំនួនមួយលើកត្រូវតែធ្វើឡើង អាស្រ័យទៅតាមទំហំនៃគម្រោង និងទំហំនៃការប៉ះពាល់ ហើយក្នុងមួយលើកៗអាចធ្វើពេញមួយថ្ងៃ ដើម្បីទុកឱកាសដល់អ្នកចូលរួមផ្ដល់យោបល់បានច្រើន។

អ្នកទទួលរងការប៉ះពាល់ពីគម្រោងត្រូវតែទទួលបានការជូនដំណឹងគ្រប់គ្រាន់ ដើម្បីអាចចូលរួមក្នុងកិច្ចប្រជុំ។ លិខិតអញ្ជើញចូលរួមប្រជុំគួរតែដាក់បញ្ចូលនូវកាលបរិច្ឆេទ ពេលវេលា និងទីតាំងនៃកិច្ចប្រជុំដែលបានស្នើឡើង ព័ត៌មានអំពីគម្រោង និងព័ត៌មានទំនាក់ទំនងពិស្ដារនៃម្ចាស់គម្រោង ឬទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

## ២.៣. លទ្ធផល

ម្ចាស់គម្រោង ត្រូវផ្ដល់ជូនមកក្រសួងបរិស្ថាន នូវឯកសារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ និងស្ថានភាពបរិស្ថាននិងសង្គម បន្ទាប់ពីបានធ្វើការផ្សព្វផ្សាយរួច ដើម្បីក្រសួងមានមូលដ្ឋានក្នុងការវិភាគក្នុងការធ្វើចំណាត់ថ្នាក់គម្រោង។ សេចក្ដីសម្រេចចិត្តក្នុងការធ្វើចំណាត់ថ្នាក់គម្រោងរបស់ក្រសួង ត្រូវតែដាក់ជាសាធារណៈឱ្យបានឆាប់ នៅពេលដែលវាចូលជាផ្លូវការ ។

ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានតម្រូវឱ្យចងក្រងនូវការវាយតម្លៃបរិស្ថាន និងសង្គមដំបូង ឬពេញលេញ ដោយផ្អែកលើលទ្ធផលនៃការប្រមូលមតិយោបល់របស់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះ ជាពិសេស លទ្ធផលនៃសិក្ខាពិគ្រោះយោបល់លើកចុងក្រោយ ។

តារាង ២៖ សេចក្ដីសង្ខេបនៃកិច្ចប្រជុំក្នុងការធ្វើចំណាត់ថ្នាក់គម្រោង

| **អ្នកណាខ្លះដែលគួរចូលរួម?** | **អ្នកណាដែលទទួលខុសត្រូវក្នុងការរៀបចំកិច្ចប្រជុំ?** | **អ្វីទៅជាលទ្ធផលនៃកិច្ចប្រជុំដែលគេប្រាថ្នាចង់បាន?** |
|---|---|---|
| អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន និងអង្គការសង្គមស៊ីវិលមូលដ្ឋាន | ម្ចាស់គម្រោង ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងអ្នកដឹកនាំសហគមន៍មូលដ្ឋាន | ដើម្បីជូនដំណឹងដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ | អ្នកដឹកនាំសហគមន៍មូលដ្ឋាន | ដើម្បីឱ្យម្ចាស់គម្រោងប្រមូលមតិត្រឡប់បឋម អំពីការធ្វើចំណាត់ថ្នាក់ |

| | | |
|---|---|---|
| | | លើគម្រោងស្នើសុំ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោង និងការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ម្ចាស់គម្រោង និង (បើបានចូលរួមរួចទៅហើយ) ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ជាទូទៅ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចូលរួមនៅក្នុងកិច្ចប្រជុំនេះ | ដើម្បីឱ្យនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រមូលមតិត្រឡប់អំពីគម្រោងស្នើសុំ សម្រាប់ពិចារណានៅក្នុងការធ្វើការសម្រេចចិត្ត នៅក្នុងការធ្វើចំណាត់ថ្នាក់គម្រោង |
| អ្នកបកប្រែ | | |

# ៣. ដំណាក់កាលកំណត់វិសាលភាពគម្រោង

## ៣.១. វិធីសាស្ត្រ និងវិសាលភាព

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយដល់សាធារណជនទូទៅ រួមមាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ទីររាជធានី-ខេត្តពាក់ព័ន្ធ អាជ្ញាធរដែនដី សង្គមស៊ីវិល តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធនានានឹងគម្រោងអភិវឌ្ឍន៍។

ការកំណត់វិសាលភាពគម្រោង គឺជាដំណាក់កាលបន្ទាប់នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការកំណត់វិសាលភាពនៃគម្រោងនេះកើតឡើងតាំងពីដំបូងនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីកំណត់បញ្ហាចម្បងៗ និងដើម្បីផ្តោត និងភ្ជាប់ជាមួយការវាយតម្លៃ ។ ដំណាក់កំណត់វិសាលភាពនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏នឹងបង្កើតផងដែរនូវលក្ខខណ្ឌការងារលម្អិត និងផែនការនៃការចូលរួមជាសាធារណៈ ។ ទាំងលក្ខខណ្ឌការងារលម្អិត និងផែនការនៃការចូលរួមជាសាធារណៈត្រូវមានការឯកភាពដោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

សវនាការជាសាធារណៈបឋមមួយ នឹងអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង ។ ទោះបីជានៅដំណាក់កាលដំបូងនេះក៏ដោយ ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែពិចារណាអំពីកិច្ចប្រជុំដោយឡែក ដើម្បីធានាថា ទាំងបុរស និងស្ត្រីមានលទ្ធភាពលើកបញ្ហានានា ដែលជាការបារម្ភរបស់ពួកគេ ។ វាជាការសំខាន់ណាស់ដែលការចូលរួមជាសាធារណៈត្រូវដាក់បញ្ចូលនូវតំណាងស្មើគ្នារវាងបុរស និងស្ត្រី ។ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការពិចារណាក្នុងការទទួលយកនូវយោបល់ពីប្រជាពលរដ្ឋ

ដែលងាយរងគ្រោះ រួមបញ្ចូល ជនក្រីក្រខ្លាំងបំផុត និងជនពិការ ។ ចំពោះ ជនជាតិដើមភាគតិច ត្រូវការពិចារណាជាពិសេស ដើម្បីធានាថា ទស្សនៈរបស់ពួកគេត្រូវបានប្រមូល និងយកទៅធ្វើការពិចារណា ។

ដំណាក់កាលកំណត់វិសាលភាពគម្រោងគឺជាឱកាសលើកដំបូង ក្នុងការរៀបចំផែនការនៃការចូលរួមជាសាធារណៈ (ដែលត្រូវបានស្គាល់ថា ផែនការនៃការចូលរួមជាសាធារណៈ) ។ ផែនការនៃការចូលរួមជាសាធារណៈត្រូវបានព្រាងឡើង ដើម្បីរៀបចំផែនការដែលម្ចាស់គម្រោងនឹងត្រូវអនុម័តនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាថា វាអនុលោមតាមកាតព្វកិច្ចក្នុងការពិគ្រោះយោបល់ជាមួយអ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ។ ផែនការនៃការចូលរួមជាសាធារណៈគួរតែត្រូវបានបង្កើតឡើង ដោយការពិគ្រោះយោបល់ជាមួយអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។

ដើម្បីឱ្យមានប្រសិទ្ធភាព ការចូលរួមជាសាធារណៈគួរតែរៀបចំឡើងជាមួយក្រុមជាក់លាក់ណាមួយ ។ គោលដៅនៃការប្រាស្រ័យទាក់ទងគួរតែមានភាពច្បាស់លាស់។ ការប្រាស្រ័យទាក់ទងជាមួយអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត គួរតែមានលក្ខណៈទាន់ពេលវេលា មានភាពច្បាស់លាស់ និងមានលក្ខណៈជាការផ្តល់ព័ត៌មាន។ ការឆ្លើយតបចំពោះកង្វល់ណាមួយ ដែលលើកឡើងអំពីកិច្ចដំណើរការនេះ គឺជាការសំខាន់ណាស់សម្រាប់ការកសាងទំនុកចិត្ត ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ រួមមានក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីររាជធានី ខេត្តពាក់ព័ន្ធ អាជ្ញាធរដែនដី សង្គមស៊ីវិល តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត ដែលមានការចាប់អារម្មណ៍នឹងគម្រោង។ ព័ត៌មានទាំងនេះគួរតែផ្តល់ឱ្យដើម្បីបង្ហាញឱ្យបានច្បាស់លាស់អំពីវិសាលភាព និងប្រភេទនៃគម្រោង ។ ព័ត៌មានត្រូវភ្ជាប់មកជាមួយនូវផែនទី គំនូសបង្ហាញ និងគំនូសបំព្រួញ (ដ្យាក្រាម) ។

ព័ត៌មានគួរតែមានភាពពាក់ព័ន្ធ និងស្ថិតនៅក្នុងទម្រង់មួយដែលអ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀតអាចយល់បាន ។ ព័ត៌មាន នេះមានន័យថា ឯកសារលក្ខណៈបច្ចេកទេស គួរតែត្រូវពន្យល់ជាភាសាសាមញ្ញ និងជាភាសារបស់ប្រជាពលរដ្ឋមូលដ្ឋាន ។ វាក៏មានន័យផងដែរថា ផែនទី និងតារាងបង្ហាញ និងកូនសៀវភៅផ្សព្វផ្សាយ គួរតែត្រូវទុកឱ្យសហគមន៍ដើម្បីពិភាក្សាបន្ថែម ។

ព័ត៌មាននេះគួរតែដាក់នៅលើអ៊ិនធើណិត ដើម្បីឱ្យសាធារណៈជន និងអ្នកពាក់ព័ន្ធដទៃទៀត អាចចូលទៅកាន់ឬស្វែងរកបាន ។ ឯកសារទាំងអស់ដែលផ្តល់ជូនអ្នកទទួលរងការប៉ះពាល់ គួរត្រូវបានចាត់ទុកថាជាព័ត៌មានដែលស្ថិតក្នុងលក្ខណៈជាកម្មសិទ្ធិសាធារណៈ ហើយអាចត្រូវបានចូលទៅកាន់ និងបែងចែកទៅកាន់ប្រជាពលរដ្ឋក្រៅសហគមន៍មូលដ្ឋាន នៅក្នុងករណីចាំបាច់ ។

ប្រសិនបើមានសំណូមពរឱ្យពន្យល់អំពីព័ត៌មានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែរៀបចំឱ្យមានកិច្ចប្រជុំមួយជាមួយអ្នកជំនាញការសមរម្យ និងសហគមន៍ ។

## តារាងទី ៣៖ សេចក្តីសង្ខេបអំពីកិច្ចប្រជុំក្នុងការកំណត់វិសាលភាពគម្រោង

| | អ្នកណាខ្លះដែលគួរចូលរួម? | អ្នកណាដែលទទួលខុសត្រូវក្នុងការរៀបចំកិច្ចប្រជុំ? | អ្វីទៅជាលទ្ធផលនៃកិច្ចប្រជុំដែលគេប្រាថ្នាចង់បាន? |
|---|---|---|---|
| **កិចប្រជុំលើកទី ១** (ដំណាក់កាលដំបូងនៃការកំណត់វិសាលភាព) | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន និងអង្គការសង្គមស៊ីវិលមូលដ្ឋាន ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត<br>អាជ្ញាធរមូលដ្ឋាន<br>គេគួរតែផ្តោតការចាប់អារម្មណ៍ជាក់លាក់ ដើម្បីដាក់បញ្ចូលស្ត្រី និងក្រុមងាយរងគ្រោះ<br>ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានសម្រប សម្រួលជាមួយអ្នកដឹកនាំសហគមន៍មូលដ្ឋាន | ដើម្បីផ្តល់ព័ត៌មានដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានានៃសំណើគម្រោង<br>ដើម្បីផ្តល់ព័ត៌មានដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានានៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br>ដើម្បីកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំបន្ទាប់ស្តីពីការកំណត់វិសាលភាពគម្រោង |
| **កិច្ចប្រជុំលើកទី ២** | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន និងកម្រិតតំបន់ និងអង្គការសង្គមស៊ីវិលថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ក្រសួងបរិស្ថាន មន្ទីរបរិស្ថានថ្នាក់ខេត្ត | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានសម្រប សម្រួលជាមួយតំណាងសហគមន៍មូលដ្ឋាន | ដើម្បីទាញយកមតិយោបល់ត្រឡប់ និងគំនិតយោបល់ជាបឋមពីអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ទៅលើបញ្ហាមួយចំនួនដែលគួរដាក់បញ្ចូលទៅក្នុងលក្ខខណ្ឌការងារ ។ |

| | | | |
|---|---|---|---|
| | អាជ្ញាធរមូលដ្ឋាន<br>ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br>អ្នកបកប្រែ<br>កិច្ចប្រជុំនេះគួរបញ្ចូលផងដែរនូវកិច្ចប្រជុំដោយឡែកពីគ្នាសម្រាប់បុរស និងស្ត្រី (ដោយមានអ្នកសម្របសម្រួលជាស្ត្រី) និងកិច្ចប្រជុំរួមគ្នា ។ | | ដើម្បីផ្តល់ព័ត៌មានដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោងនៃផែនការនៃការចូលរួមជាសាធារណៈដែលបានស្នើឡើងដែលនឹងដាក់បញ្ចូលកិច្ចប្រជុំ និងការផ្តល់ព័ត៌មាន ក្នុងពេលអនាគត |
| **កិច្ចប្រជុំលើកទី ៣** | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន និងអង្គការសង្គមស៊ីវិលមូលដ្ឋាន<br>ការនេះអាចរួមបញ្ចូលផងដែរនូវអ្នកដែលទទួលរងការប៉ះពាល់ដោយផ្ទាល់ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលមានផលប្រយោជន៍នៅក្នុងតំបន់ឬគម្រោង<br>អាជ្ញាធរមូលដ្ឋាន<br>ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានសម្របសម្រួលជាមួយតំណាងសហគមន៍មូលដ្ឋាន | ដើម្បីបង្ហាញសេចក្តីព្រាងលក្ខខណ្ឌការងារ និងស្វែងរកយោបល់ត្រឡប់លើ ថាតើមានដាក់បញ្ចូលនូវ បញ្ហានានាដែលជាការបារម្ភរបស់អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀតដែរឬទេ។ |

| | | | |
|---|---|---|---|
| | អ្នកបកប្រែ | | |

វិធីសាស្ត្រនៃការជ្រើសរើស និងការកំណត់ពេលវេលា ដែលត្រូវបានប្រើប្រាស់នៅក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធនានា និងសាធារណៈជន ផ្តល់នូវលទ្ធផលដូចខាងក្រោមៈ

- ការលើកទឹកចិត្តសម្រាប់ការផ្តល់នូវព័ត៌មានសំខាន់ៗសម្រាប់ការវាយតម្លៃ និងការបង្កើតជម្រើសនានា
- តម្លាភាពអំពីអ្វីដែលត្រូវបានស្នើឡើង និងការប៉ះពាល់ដែលអាចកើតមានរបស់វា និងវិធានការក្នុងការលើកឡើងនូវបញ្ហាទាំងនេះ និង
- សារដ៏ច្បាស់លាស់មួយទៅកាន់សាធារណៈជនទាំងអស់ ដែលមានជាតុចូលសំខាន់ៗ និងមានសារៈប្រយោជន៍នៅក្នុងដំណើរការទាំងមូលនៃកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ការកំណត់អំពីការប៉ះពាល់នានារួមបញ្ចូលៈ

- កំណត់តំបន់នានាដែលនឹងត្រូវទទួលរងការប៉ះពាល់លើបរិស្ថាន វប្បធម៌ ប្រពៃណី សង្គម និង សេដ្ឋកិច្ច
- ប្រមូលមតិយោបល់របស់អ្នកពាក់ព័ន្ធទាំងអស់ ហើយបញ្ចូលមតិយោបល់ទាំងនេះនៅក្នុងកិច្ចដំណើរការនៃការធ្វើការសម្រេចចិត្ត ។
- ត្រួតពិនិត្យគម្រោងស្នើសុំ និងពន្យល់អំពីវិធានការក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់បិរស្ថាន និងសង្គម ។
- ធ្វើការពិចារណា នៅក្នុងលក្ខណៈទូលំទូលាយ អំពីជម្រើសនានាសម្រាប់គម្រោង និងវិធានការកាត់បន្ថយ ។

កិច្ចប្រជុំ ដើម្បីកំណត់វិសាលភាពគម្រោងមានការពាក់ព័ន្ធ (ការចូលរួមដោយផ្ទាល់) ពីម្ចាស់គម្រោង សាធារណៈជន និងស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវ គឺជាយន្តការដ៏ល្អមួយសម្រាប់ពិភាក្សាអំពីវិសាលភាពជាសក្តានុពលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ជាអាទិ៍ បញ្ហានានាដែលត្រូវពិចារណានៅក្នុងដំណាក់កាលនៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន)។ រចនាសម្ព័ន្ធនៃកិច្ចប្រជុំអាចខុសគ្នាដោយអាស្រ័យលើធម្មជាតិ និងភាពស្មុគស្មាញរបស់គម្រោង ឬសកម្មភាពស្នើសុំ និងអាស្រ័យលើចំនួននៃអ្នកចូលរួមដែលមានចំណាប់អារម្មណ៍។ សម្រាប់គម្រោងដែលការប៉ះពាល់របស់វា

មានដែនកំណត់ កិច្ចប្រជុំកំណត់វិសាលភាពអាចធ្វើឡើងដូចនឹងសន្និសិទ្ធអាជីវកម្ម ដោយអ្នកចូលរួម រួមចំណែកនៅក្នុងកិច្ចពិភាក្សាក្រៅផ្លូវការទៅលើបញ្ហាដែលចោទឡើង។ កិច្ចប្រជុំកំណត់វិសាលភាព សម្រាប់គម្រោងខ្នាតធំ ឬស្មុគស្មាញ អាចទាមទារបរិយាកាសជាលក្ខណៈផ្លូវការច្រើនដូចគ្នានឹងសវនាការសាធារណៈ ដែលភាគីចាប់អារម្មណ៍ត្រូវបានផ្តល់ឱកាសក្នុងការបង្ហាញសក្ខីភាព។ គេអាចតម្រូវឱ្យមានកិច្ចប្រជុំជាសាធារណៈលើសពីមួយដង ដើម្បីធានាថា ទស្សនៈរបស់អ្នកទទួលរងការប៉ះពាល់ពីគម្រោងទាំងអស់ និងអ្នកពាក់ព័ន្ធដទៃទៀតត្រូវបានគេយកចិត្តទុកដាក់ស្តាប់ ។

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែធ្វើបទបង្ហាញអំពីគម្រោងស្នើសុំ ។ ការធ្វើបទបង្ហាញនេះអាចរួមមាន៖

- ការពិពណ៌នាជាសង្ខេបអំពីគម្រោងដែលដែលបានស្នើសុំ
- ដំណាក់កាលសំខាន់ៗនៃគម្រោង (ដំណាក់កាលរចនាគម្រោង ដំណាក់កាលមុនពេលសាងសង់ ដំណាក់កាលនៃការអនុវត្តសកម្មភាពសាងសង់ ដំណាក់កាលបិទគម្រោង/ក្រោយការបិទគម្រោង) ។
- ប្រវត្តិសង្ខេបនៃគម្រោង
- រយៈពេលដែលបានគ្រោងឡើងសម្រាប់គម្រោង
- ការវិនិយោគ និងផលប្រយោជន៍ដែលត្រូវបានរពឹងទុក (ពន្ធដារ ប្រាក់កម្រៃ ។ល។)
- ស្ថានភាពជាក់ស្តែងនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ទាក់ទងនឹងគម្រោង ។
- សេចក្តីត្រូវការសម្រាប់គម្រោង រួមបញ្ចូល ការធ្វើយុត្តិកម្មសង្ខេបនៃគម្រោង
- ជម្រើសនានាជាសក្តានុពលសម្រាប់គម្រោង និង
- ការបញ្ចៀសការប៉ះពាល់ដែលអាចកើតឡើង វិធានការកាត់បន្ថយ និងវិធានការគ្រប់គ្រង ។

ប្រភេទផ្សេងទៀតនៃកិច្ចប្រជុំកំណត់វិសាលភាពអាចរួមបញ្ចូល "សិក្ខាសាលា" ជាមួយអ្នកចូលរួមដោយក្រុមការងារតូច ក្នុងការរិះរកជម្រើស និងការរចនាផ្សេងៗ។ កិច្ចប្រជុំអាចត្រូវការអ្នកបកប្រែ ដើម្បីបកប្រែព័ត៌មានសម្រាប់អ្នកដែលមិននិយាយភាសាដូចគ្នានៅក្នុងកិច្ចប្រជុំ ដូចគ្នានឹងករណីដែលពាក់ព័ន្ធនឹងដំណាក់កាលវិភាគ និងរៀបចំនីតិវិធី នៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ វាក្យស័ព្ទបច្ចេកទេស និងវិទ្យាសាស្រ្ត និងបញ្ហានានា អាចត្រូវការផងដែរនូវការពន្យល់ដោយប្រុងប្រយ័ត្ន ។

បញ្ហាសំខាន់ៗមួយចំនួន ដែលត្រូវធ្វើការពន្យល់ដោយទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងកិច្ចប្រជុំទាំងនេះ នៅក្នុងដំណាក់កាលនៃការកំណត់វិសាលភាពគម្រោង រួមមាន៖

- ព្រំប្រទល់ ឬដែនកំណត់នៃគម្រោង
- សេចក្ដីបារម្ភសំខាន់ៗ (ដោយផ្អែកលើគម្រោងស្រដៀងគ្នា)
- កំណត់/ពន្យល់អំពីដំណាក់កាលនានានៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ការប៉ះពាល់ដែលអាចកើតឡើង និងដែលគួរឱ្យកត់សម្គាល់
- កំណត់អត្តសញ្ញាណនៃតំបន់រសើប/តំបន់សំខាន់ៗ
- កំណត់ជម្រើសនានា
- កំណត់បញ្ហា នានានៃបរិស្ថាន និងសង្គម
- កំណត់អត្តសញ្ញាណអ្នកទទួលរងការប៉ះពាល់ពីគម្រោង
- កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធដទៃទៀត
- ផែនការនៃការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ (ផែនការនៃការចូលរួមជាសាធារណៈ)
- សេចក្ដីព្រាងលក្ខខណ្ឌការងារ ។

## ៣.២. រយៈពេល

រយៈពេល ៧ថ្ងៃ ទៅ ១៥ថ្ងៃ នៃការជូនដំណឹងជាមុនគួរតែត្រូវបានផ្តល់ឱ្យមុនថ្ងៃប្រជុំអំពីការកំណត់វិសាលភាពគម្រោង អាស្រ័យទៅលើប្រភេទនៃគម្រោង ទំហំនៃការប៉ះពាល់ដែលអាចកើតមាន និងលក្ខណៈនៃអ្នកដែលអាចទទួលរងការប៉ះពាល់ ។ អំឡុងពេលនេះអាចមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអនុវត្តកិច្ចប្រជុំបន្ថែមទៀត ឬទៅតាមសំណើសុំពេលវេលាបន្ថែមទៀតរបស់អ្នកទទួលរងការប៉ះពាល់ពីគម្រោង ដើម្បីពិចារណានូវព័ត៌មានដែលផ្តល់ឱ្យដោយទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

កិច្ចប្រជុំនីមួយៗគួរតែពិភាក្សាអំពីកិច្ចប្រជុំបន្ទាប់ដែលអាចរៀបចំម្តងទៀត (ក្នុងករណីចាំបាច់) ។ ម្ចាស់គម្រោង ឬទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរតែមានភាពច្បាស់លាស់តាមដែលអាចធ្វើទៅបានអំពីជំហានបន្ទាប់ដែលត្រូវធ្វើ នៅក្នុងកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ នេះគឺជាវិធីដ៏សំខាន់ក្នុងការកសាងទំនុកចិត្តជាមួយសហគមន៍ ។

## ៣.៣. លទ្ធផល

ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍ស្តីពីការកំណត់វិសាលភាពគម្រោង និងបញ្ជូនរបាយការណ៍ដែលចងក្រងរួច ដោយភ្ជាប់នឹងឯកសារពាក់ព័ន្ធ មកក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។

របាយការណ៍ស្តីពីការកំណត់វិសាលភាពគម្រោងគួរតែដាក់បញ្ចូលនូវ សេចក្តីព្រាងលក្ខខណ្ឌការងារ សម្រាប់បញ្ហាសំខាន់ៗ ដែលត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការនៃការចូលរួមជាសាធារណៈ ។ នៅពេលដែលនាយកដ្ឋានបានពិនិត្យរបាយការណ៍ស្តីពីការកំណត់វិសាលភាពគម្រោងរួចហើយ លក្ខខណ្ឌការងារ និងផែនការនៃការចូលរួមជាសាធារណៈ ម្ចាស់គម្រោង និងអ្នកទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួនអាចបន្តការងារក្នុងជំហានបន្ទាប់គឺ ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

### តារាង ៤៖ តម្រូវការ និងការលាតត្រដាងព័ត៌មានក្នុងដំណាក់កាលកំណត់វិសាលភាពគម្រោង

| **ប្រភេទព័ត៌មានដែលត្រូវផ្តល់?** | **នណាជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន?** | **នណាគួរតែមានសិទ្ធិទទួលបានព័ត៌មាន?** |
|---|---|---|
| គំនូសព្រាងនៃគម្រោង រួមមានផែនទី សេចក្តីព្រាងផែនការ និងព័ត៌មានផ្សេងទៀតដែលអាចស្វែងរកបាន<br>សេចក្តីលម្អិតនៃគម្រោងពេលវេលាសម្រាប់ការសាងសង់ និងគំនូសព្រាងនៃការប៉ះពាល់ដែលអាចកើតឡើង (ជាទូទៅ) | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | សហគមន៍មូលដ្ឋាន អ្នកទទួលរងការប៉ះពាល់ពីគម្រោង អង្គការសង្គមស៊ីវិល ភ្នាក់ងាររដ្ឋាភិបាល បណ្តាញសារព័ត៌មាន |
| ព័ត៌មានផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រអំពីសំណើគម្រោង និងការប៉ះពាល់ដែលអាចកើតឡើង | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរតែរៀបចំអ្នកជំនាញឯកទេស និងអ្នកបកប្រែ | អ្នកទទួលរងការប៉ះពាល់ អ្នកពាក់ព័ន្ធ ឬមន្ត្រីរដ្ឋាភិបាល ដែលសំណូមពរនូវព័ត៌មានបែបនេះ |
| មតិយោបល់បឋមពីសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងភ្នាក់ងាររដ្ឋាភិបាល | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | មតិយោបល់ត្រឡប់ជាលាយលក្ខណ៍អក្សរគួរតែត្រូវបានផ្តល់ទៅកាន់សហគមន៍ឆ្លើយតបទៅនឹងមតិយោបល់បឋម ។ |

| | | |
|---|---|---|
| សេចក្តីព្រាងរបាយការណ៍កំណត់វិសាលភាពគម្រោង លក្ខខណ្ឌការងារ និងផែនការនៃការចូលរួមជាសាធារណៈ | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរតែរៀបចំ និងបែងចែកឯកសារទាំងនេះសម្រាប់ការពិភាក្សាជាមួយសហគមន៍មូលដ្ឋាន | សហគមន៍មូលដ្ឋាន (អ្នកទទួលរងការប៉ះពាល់ពីគម្រោង អ្នកពាក់ព័ន្ធដទៃទៀត) និងអាជ្ញាធរមូលដ្ឋាន<br><br>នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| របាយការណ៍កំណត់វិសាលភាពគម្រោងដែលទទួលបានការឯកភាព លក្ខខណ្ឌការងារ និងផែនការនៃការចូលរួមជាសាធារណៈ | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br><br>ក្រសួងបរិស្ថាន | សាធារណៈជនទូទៅ |

# ៤. ដំណាក់កាលស៊ើបអង្កេតគម្រោង និង ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ៤.១. វិធីសាស្ត្រ

ដូចនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោងដែរ ការធានាថាការចូលរួមជាសាធារណៈគឺមានអត្ថន័យនៅក្នុងដំណាក់កាលរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន តម្រូវឱ្យមានការធានាថា អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធ៖

១. ទីមួយ៖ ទទួលបានព័ត៌មានពេញលេញអំពីគម្រោងដែលបានស្នើសុំ រួមមានសាវតារបស់ម្ចាស់គម្រោង និងសាវតារបស់គម្រោង និងផែនការនៃការចូលរួមជាសាធារណៈ និងពេលវេលាគ្រប់គ្រាន់ ក្នុងការពិចារណាអំពីព័ត៌មាននោះ ។

២. ទីពីរ៖ មានឱកាសទទួលបានការពិគ្រោះយោបល់អំពីទស្សនៈ និងចំណេះដឹងរបស់ពួកគេ នៅក្នុងអំឡុងពេលនៃការសិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៣. ទីបី៖ មានឱកាសក្នុងការផ្តល់មតិយោបល់ត្រឡប់ទៅលើការសិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ក៏ដូចជា លទ្ធផលដែលស្វែងរកឃើញ និងការវិភាគ និង

៤. ជាចុងក្រោយ៖ មានឱកាសក្នុងការផ្តល់មតិយោបល់ជាផ្លូវការទៅលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុនពេលដែលវាត្រូវបានសម្រេចជាចុងក្រោយ និងបញ្ជូនទៅកាន់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីត្រួតពិនិត្យ ។

ចំនួននៃកិច្ចប្រជុំដែលតម្រូវឱ្យមាន ដើម្បីសម្រេចបាននូវកម្រិតដ៏មានអត្ថន័យ នៃការចូលរួមជាសាធារណៈ និងមានការប្រែប្រួលដោយអាស្រ័យទៅលើលក្ខណៈនៃគម្រោងស្នើសុំ ទីតាំងគម្រោង និងកម្រិតនៃការយល់ដឹងដែលមានស្រាប់ នៃសំណើគម្រោងនៅក្នុងចំណោមអ្នកពាក់ព័ន្ធនានា រួមបញ្ចូលកម្រិតនៃការចូលរួមជាសាធារណៈ ដែលបានរៀបចំរួចទៅហើយនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោង និងការកំណត់វិសាលភាពគម្រោង ។ ជាទូទៅ យ៉ាងហោចណាស់ កិច្ចប្រជុំចំនួន២ជាមួយអ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានានឹងត្រូវតម្រូវឱ្យមាន នៅក្នុងដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ វាគឺជាការទទួលខុសត្រូវរបស់ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងការកំណត់ ចំនួនជាក់លាក់នៃកិច្ចប្រជុំដែលត្រូវតម្រូវឱ្យមាន ដោយផ្អែកលើផែនការនៃការចូលរួមជាសាធារណៈ កាលៈទេសៈជាក់លាក់ និងការចរចាជាមួយម្ចាស់គម្រោង (ចំនួនកិច្ចប្រជុំនេះមិនត្រូវតិចជាងចំនួនដែលមានកំណត់នៅក្នុងផែនការនៃការចូលរួមជាសាធារណៈនោះទេ) ។

**ដំណាក់កាលសិក្សា៖** ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវជួបប្រជុំពិភាក្សា ធ្វើបទសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ ស្របតាមប្រកាសនេះ។

ការកំណត់វិសាលភាពនៃការសិក្សាគឺផ្អែកលើទំហំនៃការប៉ះពាល់ ទាំងនៅក្នុង និងជុំវិញទីតាំងគម្រោង ។ ចំពោះការប៉ះពាល់នៅជុំវិញទីតាំងគម្រោង អាចកំណត់ជាបឋម ត្រឹមកាំរង្វង់៥គីឡូម៉ែត្រ នៃទីតាំងគម្រោង ។ ការកំណត់ការប៉ះពាល់នេះនឹងអាស្រ័យលើលក្ខខណ្ឌការងារ គោលការណ៍ណែនាំក្នុងវិស័យជាក់លាក់ ដែលអាចត្រូវបានបង្កើតឡើង និងអាស្រ័យផងដែរទៅលើសេចក្តីព្រួយបារម្ភដែលសម្តែងដោយអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់ និងកំណត់វិសាលភាពគម្រោង។

**ផែនការគ្រប់គ្រងបរិស្ថាន៖** ការធ្វើបទបង្ហាញលើកចុងក្រោយនៅក្នុងដំណាក់កាលសម្រេចចុងក្រោយលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ត្រូវបញ្ចូលផងដែរនូវផែនការគ្រប់គ្រងបរិស្ថានដែលបានស្នើឡើង ដែលគួរតែដាក់បញ្ចូលនូវព័ត៌មានលម្អិតនៃយន្តការដោះស្រាយវិវាទរបស់សហគមន៍ ដែលបានស្នើឡើង ឬដំណើរការនៃការដោះស្រាយវិវាទ ដើម្បីអនុវត្តនៅក្នុងករណីដែលគម្រោងត្រូវបានឯកភាព ។

**ដំណាក់កាលសម្រេចចុងក្រោយលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ៖** ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកចុងក្រោយ មុននឹងបញ្ជូនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថា

នបរិស្ថានតាមបណ្តាខេត្ត។ ការធ្វើបែបនេះគឺដើម្បីឱ្យអ្នករងការប៉ះពាល់ពីគម្រោង និងអ្នកដែលមានការពាក់ព័ន្ធនឹងគម្រោង អាចផ្តល់មតិយោបល់លើកចុងក្រោយលើលទ្ធផលដែលក្រុមហ៊ុនវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានរកឃើញ មុនពេលដែលរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានសម្រេចជាចុងក្រោយ។ អ្នកចូលរួមគួរតែរួមមាន តំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីររាជធានី ខេត្តពាក់ព័ន្ធ អាជ្ញាធរដែនដី សង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀតដែលមានការពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ ដោយមានមន្ត្រីជំនាញនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាអ្នកអង្កេតការ ។

### តារាង ៥៖ ដំណាក់ស៊ើបអង្កេតគម្រោង និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន - សេចក្តីសង្ខេបពីការប្រជុំ

| លក្ខណៈ/គោលបំណងនៃការប្រជុំ | អ្នកណាខ្លះដែលគួរចូលរួម ? | អ្នកណាដែលទទួលខុសត្រូវក្នុងការរៀបចំកិច្ចប្រជុំ ? | អ្វីទៅជាលទ្ធផលនៃកិច្ចប្រជុំដែលគេប្រាថ្នាចង់បាន ? |
|---|---|---|---|
| កិច្ចប្រជុំដើម្បីផ្តល់ព័ត៌មាន (ផ្នែកដំបូងនៅក្នុងដំណាក់កាលសិក្សាគម្រោង) | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន<br>អង្គការសង្គមស៊ីវិលមូលដ្ឋាន<br>អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ<br>ម្ចាស់គម្រោង | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំសហគមន៍មូលដ្ឋាន | ដើម្បីផ្តល់ព័ត៌មានដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង ផែននៃការចូលរួមជាសាធារណៈ និងលក្ខខណ្ឌការងារសម្រាប់ការសិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។<br>ដើម្បីកំណត់ប្រភពនៃព័ត៌មាននៅក្នុងអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានាដែលអាចចូលរួមចំណែកក្នុងការស្រាវជ្រាវ និងការវិភាគនៅក្នុងការសិក្សាគម្រោង ។ |
| កិច្ចប្រជុំពិគ្រោះយោបល់ (នៅក្នុងដំណាក់កាលនៃការសិក្សា និង | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានសហការជាមួយអាជ្ញាធរមូលដ្ឋាន | ដើម្បីផ្តល់លទ្ធភាពដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ក្នុងការចូលរួមផ្តល់ចំណេះដឹង បទ |

| | | | |
|---|---|---|---|
| ការប្រមូលព័ត៌មានសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) | អង្គការសង្គមស៊ីវិលមូលដ្ឋាន<br>អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ<br>អ្នកជំនាញការផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ (ប្រសិនបើមានការស្នើសុំពីសហគមន៍ ឬត្រូវបានចាត់ទុកថាជាការចាំបាច់)<br><br>ម្ចាស់គម្រោង<br><br>អ្នកបកប្រែ | និងអ្នកដឹកនាំសហគមន៍មូលដ្ឋាន | ពិសោធន៍ និងទស្សនៈរបស់ពួកគេស្តីពីបរិស្ថានមូលដ្ឋាន និងសំណើគម្រោង ទៅក្នុងដំណើរការប្រមូលទិន្នន័យសម្រាប់ការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br><br>ដើម្បីពន្យល់ដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធ លទ្ធផលដំបូងៗ និងជាបន្តបន្ទាប់ ទាក់ទងនឹងលទ្ធផលនៃការសិក្សា ការប៉ះពាល់ដែលអាចកើតមាននៃគម្រោង និងការវិភាគ រួមបញ្ចូល វិធានការដើម្បីដោះស្រាយការប៉ះពាល់ទាំងនេះ<br><br>ដើម្បីផ្តល់ឱកាសដល់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ដើម្បីឆ្លើយតបចំពោះ និងផ្តល់ទស្សនៈរបស់គេទៅលើផទ្ធផល និងការវិភាគទាំងអស់ ។ |
| កិច្ចប្រជុំស្តីពីសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន<br>អង្គការសង្គមស៊ីវិលមូលដ្ឋាន | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយតំណាងសហគមន៍មូលដ្ឋាន | ដើម្បីបង្ហាញសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពន្យល់អំពីលទ្ធផលនៃការសិក្សា (រួមបញ្ចូល ការប៉ះពាល់ ជម្រើសនានា ការបញ្ចៀស និងវិធានការកាត់បន្ថយ និងផែនការគ្រប់គ្រងបរិស្ថាន) និង |

| | | | |
|---|---|---|---|
| | អាជ្ញាធររដ្ឋាភិបាលថ្នាក់ជាតិ និង អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ<br>អ្នកជំនាញការផ្នែកបច្ចេកទេស និង វិទ្យាសាស្ត្រ<br>ម្ចាស់គម្រោង<br>អ្នកបកប្រែ | | របៀបដែលទស្សនៈរបស់អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវបានដាក់បញ្ចូល ។<br><br>ដើម្បីផ្តល់ព័ត៌មានអំពីសំណង និងផលប្រយោជន៍ដទៃទៀត ដែលបានស្នើឡើងសម្រាប់អ្នកទទួលរងការប៉ះពាល់ ។<br><br>ដើម្បីផ្តល់ឱកាសដល់អ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា ក្នុងការឆ្លើយតបចំពោះសេចក្តីព្រាងរបាយការណ៍វាយតម្លៃ មុនពេលដែលវាត្រូវបានសម្រេចចុងក្រោយ និងបញ្ជូនទៅអាជ្ញាធរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ |
| កិច្ចប្រជុំដើម្បីសម្រេចជាចុងក្រោយលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | អ្នកទទួលរងការប៉ះពាល់នៅកម្រិតមូលដ្ឋាន<br>អង្គការសង្គមស៊ីវិលមូលដ្ឋាន<br>ម្ចាស់គម្រោង<br>អ្នកបកប្រែ | ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយតំណាងសហគមន៍មូលដ្ឋាន | ដើម្បីបង្ហាញនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយ (ដោយរួមបញ្ចូលផែនការគ្រប់គ្រងបរិស្ថាន) |

## ៤.២. រយៈពេលកំណត់

**ដំណាក់កាលសិក្សា៖** កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ នៅក្នុងអំឡុងពេលនៃការសិក្សា គួរមានរយៈពេលពីមួយខែទៅបីខែសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរយៈពេលបីខែទៅ៦ខែ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។ រយៈពេលកំណត់នេះគឺគ្រាន់តែជាការណែនាំប៉ុណ្ណោះ ។ លក្ខខណ្ឌតម្រូវជាបឋមសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ គឺថា ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវពិចារណាឱ្យបានពេញលេញនូវការប៉ះពាល់ដល់បរិស្ថាន សង្គម សុខភាព និងសេដ្ឋកិច្ចនៃគម្រោង ឬសកម្មភាពដែលបានស្នើឡើង។ ពេលខ្លះ ការសិក្សាអាចចំណាយពេលលើសពី៦ខែ។ ដំណាក់កាលនៃការសិក្សាគួរតែដាក់បញ្ចូលនូវអត្ថបទព័ត៌មានជាទូទៅនៃអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ។

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននឹងត្រូវដោះស្រាយបញ្ហានានា ដែលត្រូវបានលើកឡើងនៅក្នុងលក្ខខណ្ឌការងារ និងត្រូវអនុវត្តផែនការនៃការចូលរួមជាសាធារណៈ ។

**ផែនការគ្រប់គ្រងបរិស្ថាន៖** នៅពេលដែលដំណាក់កាលនៃការសិក្សាបានកំណត់អំពីផលប៉ះពាល់ដែលអាចកើតឡើងនៃគម្រោងដែលបានស្នើឡើង ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននឹងពិចារណាអំពីជម្រើសនានាចំពោះគម្រោង ក៏ដូចជាវិធីសាស្ត្រក្នុងការកាត់បន្ថយ ឬបញ្ចៀសការប៉ះពាល់អវិជ្ជមាន ។ ការនេះនឹងតម្រូវឱ្យមានការបង្កើតនូវផែនការគ្រប់គ្រងបរិស្ថាន។ ផែនការគ្រប់គ្រងបរិស្ថានទាំងនេះ ដែលនឹងដាក់បញ្ចូលផងដែរនូវលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ និងការប្តេជ្ញាចំពោះអ្នកទទួលរងការប៉ះពាល់ ដោយម្ចាស់គម្រោង គួរតែត្រូវរៀបចំដោយពិគ្រោះយោបល់ជាមួយអ្នកទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ។

**ដំណាក់កាលសម្រេចជាចុងក្រោយលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖** ម្ចាស់គម្រោងត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់រួមមួយ ដោយអញ្ជើញអ្នកពាក់ព័ន្ធទាំងអស់ចូលរួម ដែលអាចធ្វើក្នុងរយៈ ពេល១ថ្ងៃទៅ២ថ្ងៃទៅតាមប្រភេទគម្រោង និងទំហំនៃការប៉ះពាល់ និងត្រូវរៀបចំពេលវេលាដោយមានពេលវេលាគ្រប់គ្រាន់មុនពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានសម្រេចជាចុងក្រោយ ដើម្បីដាក់បញ្ចូលមតិយោបល់ត្រឡប់ជាចុងក្រោយ ។

សិក្ខាសាលាពិគ្រោះយោបល់លើកចុងក្រោយគួរដាក់បញ្ចូលផងដែរនូវ បទបង្ហាញមួយនៃផែនការគ្រប់គ្រងបរិស្ថានដែលបានស្នើឡើង ដែលគួរតែដាក់បញ្ចូលនូវសេចក្តីលម្អិតនៃយន្តការដោះស្រាយវិវាទរបស់សហគមន៍ ដែលបានស្នើឡើង ឬនីតិវិធីនៃការដោះស្រាយវិវាទ ដើម្បីអនុវត្តនៅក្នុងករណីដែលគម្រោងទទួលបានការឯកភាព ។

## ៤.៣. លទ្ធផល

ម្ចាស់គម្រោងត្រូវដាក់បញ្ចូលធាតុចូលពីអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ដែលបានទទួលនៅក្នុងអំឡុងពេលនៃការសិក្សាគម្រោង ព្រមទាំងមតិយោបល់មកពីបទបង្ហាញនៃសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានបង្ហាញទៅកាន់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា ទៅក្នុងកំណែចុងក្រោយនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងត្រូវអនុលោមទៅតាមប្រកាសស្តីពីគោលការណ៍ណែនាំទូទៅសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ លេខ ៣៧៦ ប្រក.ប.ស្ថ (២០០៩)។

បន្ទាប់មក របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបញ្ជូនទៅក្រសួងបរិស្ថានដើម្បីវាយតម្លៃ ។ យោងតាមអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ ១៩៩៩ ពុំមានអំឡុងពេលកំណត់សម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះទេ។ ដំណាក់កាលនៃការចាត់ចំណាត់ថ្នាក់គម្រោង ការកំណត់វិសាលភាពគម្រោង និងដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តដោយទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយអំឡុងពេលរបស់វានឹងត្រូវពឹងអាស្រ័យទៅលើភាពស្មុគស្មាញនៃគម្រោង ។

ធាតុចូលពីសាធារណជនឆ្លុះបញ្ចាំងពីការកែប្រែនៅក្នុងការវាយតម្លៃគម្រោង ឬកម្មវិធី ឬការប្តេជ្ញាសម្រាប់ការកាត់បន្ថយផលប៉ះពាល់ ។ ក្រសួងបរិស្ថានកត់ត្រានូវជំហ៊ានដាក់លាក់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយសាធារណៈជន និងអ្នកពាក់ព័ន្ធដទៃទៀត ហើយនិងពេលវេលានៃការចូលរួមទាំងនោះ ទាំងមុនការរៀបចំ និងក្នុងអំឡុងពេលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ សេចក្តីសង្ខេបស្តីពីសកម្មភាពសាធារណៈ អ្នកសង្កេតការណ៍ ចំនួនអ្នកចូលរួម អង្គការពាក់ព័ន្ធ សេចក្តីបារម្ភដែលបានលើកឡើង ការឆ្លើយតបនឹងយោបល់ និងប្រសិនបើមានតម្រូវការ ច្បាប់ចម្លងការផ្តល់យោបល់ជាលាយលក្ខអក្សរ គួរតែភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ របាយការណ៍ស្តីពីការ

ផ្តល់យោបល់ដែលទទួលបានតាមរយៈវិធីសាស្ត្រណាមួយដែលបានកំណត់ខាងលើ ត្រូវតែមានភាពច្បាស់លាស់ដើម្បីឱ្យអ្នកពិនិត្យ និងសាធារណជន វាយតម្លៃទៅលើភាពឆ្លើយតបទៅនឹងយោបល់ទាំងនោះ រួមទាំង ថាតើត្រូវបានគេយល់ឬទេ ថាតើសមស្របឬទេ និងហេតុអ្វី និងប្រសិនបើសមស្រប តើសកម្មភាពអ្វីខ្លះនឹងត្រូវប្រើក្នុងការឆ្លើយតបនឹងយោបល់ទាំងនោះ ហើយថាតើសកម្មភាពទាំងនោះគ្រប់គ្រាន់នឹងដោះស្រាយការព្រួយបារម្ភទាំងអស់ដែរឬទេ។ នីតិវិធីជាច្រើនអាចនឹងទទួលយកបាននៅក្នុងការសង្ខេប ឬ ដាក់បញ្ចូលអត្ថបទចម្លងពិតប្រាកដ និងឯកសារថតចម្លងជាលាយលក្ខអក្សរ និងផ្ទាល់មាត់ និងបង្ហាញពីភាពឆ្លើយតបតាមរយៈការពិពណ៌នាតារាង និងឯកសារយោងនានា ជាមួយនឹងការកែប្រែណាមួយ។

អនុផ្នែកខាងក្រោមគួរតែត្រូវដាក់បញ្ចូលនៅក្នុងផ្នែកស្តីពី "ការលាតត្រដាងព័ត៌មាន និងការចូលរួមជាសាធារណៈ" នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖

- **សេចក្តីផ្តើម**
  - សាវតា និងគោលបំណងនៃគម្រោង
  - គោលដៅនៃការពិគ្រោះយោបល់នៅក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
  - លក្ខខណ្ឌតម្រូវផ្នែកច្បាប់នានា

- **វិធីសាស្ត្រ និងអភិក្រម**
  - រួមមាន របៀបដែលសេចក្តីត្រូវការនៃក្រុមជាក់លាក់ណាមួយ (ស្ត្រី កុមារ ជនជាតិភាគតិច ។ល។) ត្រូវបានកំណត់ និងពិចារណា ។

- **សេចក្តីសង្ខេបនៃសកម្មភាពពិគ្រោះយោបល់ដែលត្រូវបានអនុវត្ត**
  - ទិដ្ឋភាពទូទៅនៃរបៀបដែលការពិគ្រោះយោបល់ត្រូវអនុវត្ត ពេលវេលា ជាមួយអ្នកណា និងអនុវត្តដោយអ្នកណា
  - សេចក្តីសង្ខេបនៃគំនិតយោបល់នៃបុគ្គលនានា ដែលត្រូវបានពិគ្រោះយោបល់

- **លទ្ធផលនៃការពិគ្រោះយោបល់ នៅក្នុងអំឡុងពេលនៃការកំណត់វិសាលភាពគម្រោង**
  - បញ្ហានានាដែលត្រូវបានកំណត់ដោយអ្នកពាក់ព័ន្ធ
  - របៀបដែលបញ្ហាទាំងនេះត្រូវបានយកទៅពិចារណា

- **លទ្ធផលនៃការពិគ្រោះយោបល់ស្តីពីការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន**
  - បញ្ហានានាដែលត្រូវបានកំណត់ដោយអ្នកពាក់ព័ន្ធ
  - របៀបដែលបញ្ហាទាំងនេះត្រូវបានយកទៅពិចារណា

- **លទ្ធផលនៃការពិគ្រោះយោបល់នៅក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**
  - បញ្ហានានាដែលត្រូវបានកំណត់ដោយអ្នកពាក់ព័ន្ធ
  - របៀបដែលបញ្ហាទាំងនេះត្រូវបានយកទៅពិចារណា
  - មតិយោបល់លើផែនការគ្រប់គ្រងបរិស្ថាន

- **អនុសាសន៍នានាសម្រាប់ការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងដំណើរការនៃការដោះស្រាយវិវាទនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការ**

- **តារាងឧបសម្ព័ន្ធ៖**
  - សេចក្តីសង្ខេបនៃគម្រោងដែលត្រូវបានបង្ហាញនៅក្នុងអំឡុងពេលនៃការពិគ្រោះយោបល់ជាសាធារណៈ (គួរតែផ្តល់នូវការពិពណ៌នាអំពីគម្រោងជាសង្ខេប ការប៉ះពាល់នៃគម្រោងដែលអាចកើតឡើង និងវិធានការកាត់បន្ថយសម្រាប់ការប៉ះពាល់ដែលគួរឱ្យកត់សម្គាល់នានា)
  - ដំណើរការនីតិវិធីលម្អិត/កំណត់ហេតុ សម្រាប់សកម្មភាពពិគ្រោះយោបល់នីមួយៗ
  - បញ្ជីពេញលេញនៃអ្នកចូលរួមសម្រាប់សកម្មភាពពិគ្រោះយោបល់នីមួយៗ ។

## ៥.ដំណាក់កាលពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការធ្វើសេចក្តីសម្រេច

### ៥.១. វិធីសាស្ត្រ និងវិសាលភាព

យោងតាមប្រកាសពាក់ព័ន្ធ នាយកដ្ឋានវាយតម្លៃហេត់ប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានខេត្ត ត្រូវចុះទស្សនៈកិច្ចទីតាំងគម្រោង ក្រោយពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានបញ្ជូនមក ។ ពុំមានលក្ខខណ្ឌតម្រូវអ្វីឡើយ នៅក្រោមប្រកាសនោះ ដើម្បីឱ្យនាយកដ្ឋានវាយតម្លៃហេត់ប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានខេត្ត ក្នុងការអនុវត្តនូវកិច្ចប្រជុំស្តីពីការចូលរួមជាសាធារណៈ មុនពេលត្រួតពិនិត្យលើរបាយការណ៍វាយតម្លៃហេត់ប៉ះពាល់បរិស្ថាន ។

កិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញមានពីរដំណាក់កាលះ

(១). កិច្ចប្រជុំពិនិត្យផ្ទៃក្នុងក្រសួងបរិស្ថាន រួមបញ្ចូល នាយកដ្ឋានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង

(២). កិច្ចប្រជុំពិនិត្យផ្ទៃក្នុង និងអន្តរក្រសួងះ កិច្ចប្រជុំនេះតែងធ្វើឡើងដោយមានអ្នកចូលរួមពីក្រុមការងាររបស់ ក្រសួងបរិស្ថាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងជំនាញការជាតិនិងអន្តរជាតិ។

ការជូនដំណឹងជាមុន និងពេលវេលាគ្រប់គ្រាន់ (រយៈពេល) សម្រាប់ឱកាសពិនិត្យ និងផ្តល់យោបល់នីមួយៗ ដែលផ្តល់ពេលសមល្មមសម្រាប់សាធារណជនពិនិត្យ ឬរកជំនួយពីខាងក្រៅក្នុងការពិនិត្យ (ដូចជាការប្រឹក្សាយោបល់ពីអ្នកជំនាញឯករាជ្យ)។ ជាទូទៅ ក្រសួងបរិស្ថានផ្តល់ពេលឱ្យសាធារណជនពី ៥-១០ ថ្ងៃ សម្រាប់រយៈពេលផ្តល់យោបល់នីមួយៗ ដែលអាចវែងជាង ឬខ្លីជាងទៅតាមការយល់ឃើញរបស់ក្រសួង។ រយៈពេលផ្តល់យោបល់មិនត្រូវតិចជាង០៥ថ្ងៃនោះទេ។ គួរតែមានឱកាសយ៉ាងច្បាស់នៅក្នុងការបន្ថែមពេលវេលាផ្តល់យោបល់ នៅពេលដែលមានការស្នើឡើងពីសាធារណជន ។

### ៥.២. រយៈពេល

- ពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលទទួលរងការប៉ះពាល់ អាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ដោយមានរយៈពេលពី ៣ថ្ងៃ ទៅ ៥ថ្ងៃ

- ការប្រជុំពិនិត្យ និងផ្ដល់យោបល់របស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផ្អែកលើអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ឆ្នាំ២០១៥ និងប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ រយៈពេលនៃកិច្ចប្រជុំនេះគឺនឹងត្រូវធ្វើឡើងរយៈពេលកន្លះថ្ងៃ ក្នុងចន្លោះពេល ៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមន្ត្រីនាយកដ្ឋានចុះពិនិត្យទីតាំងជាក់ស្ដែងរួច។
- ប្រជុំពិនិត្យ និងផ្ដល់យោបល់របស់ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផ្អែកលើសេចក្ដីសម្រេចស្ដីពីការបង្កើត ការកែសម្រួលសមាសភាពក្រុមការងារសម្របសម្រួល ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ រយៈពេលកិច្ចប្រជុំនេះមានរយៈពេល១ថ្ងៃ ក្នុងចន្លោះពេល១០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិនិត្យឃើញថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្ខេបដំបូង ឬពេញលេញ ដែលបានកែតម្រូវរួច មានភាពត្រឹមត្រូវទទួលយកបាន។
- ប្រជុំពិនិត្យ និងផ្ដល់យោបល់របស់អន្តរក្រសួង លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ រយៈពេលនៃកិច្ចប្រជុំនេះមានរយៈពេល១ថ្ងៃ ក្នុងចន្លោះពេល១០ថ្ងៃនៃថ្ងៃធ្វើការ។

## ៥.៣. លទ្ធផល

លទ្ធផលនៃដំណាក់កាលត្រួតពិនិត្យ និងវាយតម្លៃគម្រោង គឺត្រូវចេញជារបាយការណ៍ជូនរដ្ឋមន្ត្រីស្ដីពីថាតើគម្រោងគួរតែទទួលបាននូវការឯកភាពឬយ៉ាងណា រួមជាមួយលក្ខខណ្ឌនានានៃការឯកភាព ។ របាយការណ៍ដែលរៀបចំជូនរដ្ឋមន្ត្រីគួរតែដាក់បញ្ចូលនូវការយោងទៅលើផែនការគ្រប់គ្រងបរិស្ថាន និងយន្តការដោះស្រាយវិវាទ និងលទ្ធផលបន្ថែមទៀតនៃផែនការនៃការចូលរួមជាសាធារណៈ ។

សេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីគួរតែត្រូវជូនជាដំណឹងដល់ម្ចាស់គម្រោង និងដាក់នៅលើគេហទំព័រនៃក្រសួងបរិស្ថាន រួមជាមួយផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោង ។ អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធនានា គួរតែត្រូវទទួលបានដំណឹងអំពីសេចក្ដីសម្រេចនេះ ដែលបានធ្វើឡើងដោយរដ្ឋមន្ត្រី ក្នុងរយៈពេល ៧ ថ្ងៃ នៃការសម្រេច ។

វាគឺជាការទទួលខុសត្រូវរបស់អាជ្ញាធរវាយតម្លៃហេត់ប៉ះពាល់បរិស្ថាន ក្នុងការធានាថា របាយការណ៍វាយតម្លៃហេត់ប៉ះពាល់បរិស្ថានចុងក្រោយ (រួមជាមួយឯកសារនានា និងឧបសម្ព័ន្ធ រួមបញ្ចូលផែនការគ្រប់គ្រងបរិស្ថាន) ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាន ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើ

ទៅបាន នៅពេលដែលគេទទួលបាន ។ ឯកសារសំខាន់ៗ(ជាអប្បបរមា)គួរតែដាក់ឱ្យសាធារណៈជនអាចស្វែងរកបាននៅក្នុងដំណាក់កាលនេះ រួមមាន៖

- របាយការណ៍វាយតម្លៃហេត់ប៉ះពាល់បរិស្ថានចុងក្រោយ
- របាយការណ៍កំណត់វិសាលភាពគម្រោង និងលក្ខខណ្ឌការងារ ដែលទទួលបានការឯកភាព និង
- ផែនការនៃការចូលរួមជាសាធារណៈ ។

# ៦. ដំណាក់កាលអង្កេតតាមដានបរិស្ថាន

## ៦.១. វិធីសាស្ត្រ

នៅពេលដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬដំបូង ទទួលបានការឯកភាព ដោយក្រសួងបរិស្ថាន ពេលនោះក្រសួងនឹងចេញវិញ្ញាបនបត្រឯកភាព ដែលនឹងរួមបញ្ចូលនូវផែនការគ្រប់គ្រងបរិស្ថាន លក្ខខណ្ឌ និងកាតព្វកិច្ចរបស់ម្ចាស់គម្រោង។ ការទាំងនេះនឹងត្រូវចងក្រងនៅក្នុងអំឡុងពេលនៃការសាងសង់ និងប្រតិបត្តិការនៃគម្រោង ។ បន្ថែមលើនេះ គឺអាចមានកាតព្វកិច្ចសម្រាប់ការបិទគម្រោង និងការស្តារបរិស្ថានឡើងវិញ ។ ការទាំងនេះនឹងត្រូវដាក់បញ្ចូលនៅក្នុងកិច្ចសន្យាការពារបរិស្ថាន និងវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬដំបូង ។

សម្រាប់គម្រោងនានាដែលទទួលបាន ការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិ-ស្ថាន និងបន្តទៅកាន់ការអនុវត្តការងារ វាគឺជាការសំខាន់ណាស់សម្រាប់ទាំងលទ្ធផលផ្នែកបរិស្ថាននិងសង្គមនៃគម្រោង និងសម្រាប់ភាពត្រឹមត្រូវនៃប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលថា ការសាងសង់ប្រតិបត្តិការ និងការបិទគម្រោង អនុលោមទៅតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌនៃការឯកភាព ដែលចេញដោយក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធដទៃទៀត ។

ដើម្បីធានាឱ្យមានការអនុលោមតាម និងដើម្បីសម្រេចបាននូវការប្តេជ្ញានៅក្នុងរបាយការណ៍វាយតម្លៃហេត់ប៉ះពាល់បរិស្ថាន គឺតម្រូវឱ្យមានប្រព័ន្ធអង្កេតតាមដាន ដែលមានការពាក់ព័ន្ធទាំងការអង្កេតតាមដានផ្ទៃក្នុងដោយអ្នកគ្រប់គ្រងគម្រោង (ឬភាគីទីបីជាអ្នកជំនាញការ) និងការអង្កេតតាមដានឯករាជ្យ

ដោយភាគីខាងក្រៅ ។ ការអង្កេតតាមដានខាងក្រៅនេះអាចអនុវត្តដោយភ្នាក់ងាររដ្ឋាភិបាល (ថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ) អង្គការសង្គមស៊ីវិល និងសហគមន៍ ។

## ៦.២. ការអង្កេតតាមដាន

ការអង្កេតតាមដានគឺសកម្មភាពបន្តជានិរន្ត។ ការអង្កេតតាមដាននឹងជួយធ្វើឱ្យសហគមន៍ពេញចិត្ត ក្នុងន័យដែលថា គម្រោងកំពុងធ្វើប្រតិបត្តិការស្របតាមលក្ខខណ្ឌនៃការឯកភាព។ វាក៏ជួយផងដែរក្នុងឆ្លើយតបចំពោះ និងកែតម្រូវបញ្ហា និងក្តីបារម្ភណ៍ ដែលអាចកើតឡើងនៅក្នុងអំឡុងពេលនៃការអនុវត្ត មុនពេលដែលផលវិបាកធ្ងន់ធ្ងរកើតមានឡើង។ ការអង្កេតតាមដានក៏ផ្តល់លទ្ធភាពផងដែរក្នុងការកំណត់អំពី៖

- ភាពទន់ខ្សោយនៅក្នុងវិធានការកាត់បន្ថយ និងការគ្រប់គ្រង (ដូចជា វិធានការនានាអាចត្រូវបានអនុវត្តទៅតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិ-ស្ថាន ប៉ុន្តែពុំទទួលបានលទ្ធផលដែលរំពឹងទុកនៃការបញ្ចៀស ឬការកាត់បន្ថយការប៉ះពាល់នោះទេ)
- ការប៉ះពាល់ថ្មី ដែលមិនបានដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងវិធានការកាត់បន្ថយសមរម្យ និងការកែសម្រួលលើផែនការគ្រប់គ្រងបរិស្ថាន និង
- លទ្ធផលនៃការស្វែងរកឃើញ និងបទពិសោធន៍ដែលអាចមានភាពពាក់ព័ន្ធសម្រាប់ការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងដែលស្រដៀងគ្នា ឬគម្រោងដែលស្ថិតនៅក្នុងទីតាំងស្រដៀងគ្នា ។

### ដំណាក់កាលមុនសាងសង់

ម្ចាស់គម្រោង និងអ្នកសាងសង់គម្រោង ត្រូវតែរៀបចំកិច្ចប្រជុំមួយ ឬ លើសពីមួយ (ប្រសិនបើចាំបាច់) ជាមួយអ្នកទទួលរងការប៉ះពាល់ពីគម្រោងមុនពេលចាប់ផ្តើមការងារសាងសង់ណាមួយលើទីតាំងគម្រោង ដើម្បីឱ្យប្រជាពលរដ្ឋអាចយល់បានច្បាស់ ។ កិច្ចប្រជុំនេះគួរតែផ្តល់ព័ត៌មានលម្អិតអំពីតារាងពេលវេលាសម្រាប់ការងារសាងសង់ដែលបានស្នើឡើង។ គេគួរតែផ្តល់ព័ត៌មានលម្អិតអំពីបញ្ហានានា ដូចជាចំនួនឡានដឹកទំនិញ និងរថយន្តសំណង់ ចំនួនកម្មករ ម៉ោងសាងសង់ រយៈពេលនៃការសាងសង់ ហើយត្រូវពន្យល់អំពីការប៉ះពាល់ ដែលអាចកើតឡើងចំពោះអ្នកទទួលរងការប៉ះពាល់ពីគម្រោង និងវិធានការកាត់បន្ថយផលប៉ះពាល់ច្បាស់លាស់ ។

### ដំណាក់កាលសាងសង់

អ្នកសាងសង់គម្រោងគួរតែលម្អិតអំពីផែនការនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលនៃការសាងសង់ និងត្រូវរៀបចំកិច្ចប្រជុំចំនួនមួយ ឬ ច្រើន (ប្រសិនបើចាំបាច់) ដើម្បីឱ្យប្រជាពលរដ្ឋអាចយល់បានច្បាស់លាស់ ។ ការនេះគួរតែផ្តល់ព័ត៌មានលម្អិតអំពីយន្តការនានា សម្រាប់ទាក់ទងជាមួយសហគមន៍មូលដ្ឋាន (ដូចជា គណៈកម្មការពិគ្រោះយោបល់សហគមន៍) និងសម្រាប់ដោះស្រាយវិវាទ/សំណងការខូចខាត ។

### ដំណាក់កាលប្រតិបត្តិការ

ដំណាក់កាលនៃការប្រតិបត្តិ ត្រូវមានរយៈពេលមួយជីវិតនៃគម្រោង និងគួរតែមានផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។ ផែនការគ្រប់គ្រងបរិស្ថាននេះនឹងដាក់បញ្ចូលនូវព័ត៌មានលម្អិតសម្រាប់ការគ្រប់គ្រងនូវផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោង ។ នៅក្នុងដំណាក់កាលនៃប្រតិបត្តិការគម្រោង គឺតម្រូវឱ្យមានការអង្កេតតាមដានទៅលើសារធាតុបំពុល និងសំណល់ ដែលបង្កើតឡើងដោយប្រតិបត្តិការរបស់គម្រោង ។ ការបំពុលនេះអាចជា ការបំពុលខ្យល់ ការបំពុលសំឡេង ការបំពុលចក្ខុ និងការបំពុលទឹក ។ សំណល់អាចជា សំណល់ដែលអាចកែច្នៃឡើងវិញ សំរាមទូទៅ ឬសំណល់ដែលមានជាតិពុល ឬដែលគ្រោះថ្នាក់ ។

បទប្បញ្ញត្តិគួរតែត្រូវបានបង្កើតឡើង សម្រាប់ការចូលរួមពីសំណាក់អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការអង្កេតតាមដាន និងការអនុលោមតាម ផែនការគ្រប់គ្រងបរិស្ថាន ។ សម្រាប់គម្រោងធំៗ ដែលអាចមានផលប៉ះពាល់ជានិរន្ត ម្ចាស់គម្រោងគួរតែពិចារណាក្នុងការបង្កើតនូវគណៈកម្មការពិគ្រោះយោបល់សហគមន៍ ។

## ៧. ការផ្អាកគម្រោង ការបិទគម្រោង និងដំណាក់កាលក្រោយការបិទគម្រោង

ការចូលរួមជាសាធារណៈបន្តធ្វើ នៅក្នុងអំឡុងពេលប្រតិបត្តិការគម្រោង ។ អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ពន្ធ័គួរទទួលបានការពិគ្រោះយោបល់ និងចូលរួមនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន សម្រាប់ការបិទ និងការផ្អាកនៃគម្រោង។

សម្រាប់គម្រោង ដូចជា ទីតាំងរ៉ែ និងឧស្សាហកម្មធុនធ្ងន់ ដែលមានអំឡុងពេលផ្អាក និងក្រោយការបិទគម្រោង អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ពន្ធ័ ត្រូវមានការចូលរួមនៅក្នុងអំឡុងពេលនៃការអង្កេតតាមដាននេះ។ គម្រោងស្តារបរិស្ថានឡើងវិញនេះត្រូវរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវនានាក្នុងការ

អង្កេតតាមដានរយៈពេលខ្លី និងវែង ដោយបញ្ចូលនូវការអង្កេតតាមដាន និងការគ្រប់គ្រងនៅពល់ការកើតឡើងនានាទាក់ទងនឹងកាកសំណល់ និងទឹកដែលមានជាតិពុល ។ អំឡុងពេលនៃការអង្កេតតាមដានក្រោយការបិទគម្រោង អាចនឹងបន្លាយពេលលើសពី៥ឆ្នាំ និងត្រូវបានកំណត់ដោយពឹងផ្អែកទៅលើ ស្តង់ដារអន្តរជាតិ។

ការអង្កេតតាមដាននៃការបិទគម្រោង និងក្រោយការបិទនៃគម្រោង ត្រូវផ្តល់នូវឯកសារស្តីពីដំណើរការនៃការបិទគម្រោង និងកិច្ចប្រឹងប្រែងនៃការស្តាឡើងវិញ។ ជាតុផ្សំនៃកម្មវិធីអង្កេតតាមដានត្រូវបញ្ចូលនូវៈ

1. ការធ្វើអធិការកិច្ចទៅលើលក្ខខណ្ឌរូបសាស្ត្រ (ឧទាហរណ៏ សម្រាប់ជាភស្តុតាងនៃការច្រោះដី និងការបាក់ដី) នៅចុងបញ្ចប់នៃក្រោយការបិទគម្រោងនៅរដូវភ្លៀងធ្លាក់ដំបូង
2. ការធ្វើអធិការកិច្ចទៅលើការដាំដុះបន្ទាប់ពីក្រោយការបិទគម្រោងក្នុងឆ្នាំដំបូង
3. ក្រោយរយៈពេល២ឆ្នាំ ការវាយតម្លៃនូវប្រសិទ្ធិភាពនៃកិច្ចប្រឹងប្រែងនៃការស្តាឡើងវិញ (ឧទាហរណ៏ ចំនួន និងប្រភេទនៃដំពូករុក្ខជាតិ កំពស់រុក្ខជាតិ ផលិតភាព)
4. ការបង្ហាញឱ្យឃើញថា ត្រូវសម្រេចឱ្យបាននូវគោលដៅនានា នៃគុណភាពទឹក និង
5. ការវាយតម្លៃនៃភាពគ្រប់គ្រាន់ និងការបំពេញមុខងារ នៃរចនាសម្ព័ន្ធបំពុងបង្ហូរទឹក និងប្រព័ន្ធត្រួតពិនិត្យកករ ។

ការអភិវឌ្ឍន៍គម្រោងនានាត្រូវរួមបញ្ចូលនូវ អ្នកទទួលរងការប៉ះពាល់ពីគម្រោង និងអ្នកពាក់ពន្ធ័ដទៃទៀត ។